# ការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម



រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានគាំទ្រជាគោលការណ៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសហការគ្នារៀបចំពិព័រណ៍ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងអភិវឌ្ឍសារមន្ទីរតាមបណ្តា ២៤ខេត្ត-ក្រុង។ ជំហានដំបូង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំដាក់តាំងពិព័រណ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខេត្តចំនួន៥ ដូចជា ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ព្រះសីហនុ និងតាកែវ ដោយធ្វើការចងក្រងឯកសារស្តីពីរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រវត្តិភូមិបូជនីយដ្ឋានដំកល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម រណ្តៅសាកសព និងគុកខ្មែរក្រហមដែលនៅរាយប៉ាយទូទាំងប្រទេសកម្ពុជា។ ពិព័រណ៍នេះជាការអភិវឌ្ឍន៍ដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជាដែលខំពុះពារដើម្បីស្វែងរកការផ្សះផ្សានិងយុត្តិធម៌និងជាការអប់រំដល់យុវជនជំនាន់ក្រោយ។ គម្រោងនេះមិនត្រឹមតែអប់រំដល់សាធារណជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយធានាថាប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាការចងចាំមួយដែលមិនអាចបំភ្លេចបាន។

គម្រោងនេះបានទទួលការឧបត្ថម្ភគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋាភិបាលអាល្លឺម៉ង់ និងអមជំនួយដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋ អាមេរិក។ មូលនិធិដែលទទួលបានសម្រាប់អនុវត្តគម្រោងនេះ បានមកពីក្រសួងរបស់សហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ តាមរយៈអង្គភាពគាំពារជនរងគ្រោះនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។

# ការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម

រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា

**ក្រុមស្រាវជ្រាវជាតិ**
ម៉ែន ពិចិត្រ
សេង គន្ធី
ជាង ចាន់និមល
ទេស ឈឿន
ហោ កុសល
គឹមស្រួយ សុខវិសាល
ម៉ម សុជាត
លី កុកឆាយ
ស៊ីវ សាវីណា
ជី ទេវិទ្ធិ
លន់ ដាលីន
ឆាយ ដាវីន

**ក្រុមស្រាវជ្រាវអន្តរជាតិ**
អ្នកនាង វីនីតា រ៉ាម៉ានី, Access to Justice Asia, សាំងហ្គាពួរ
សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន និងក្រុមការងារ, សាកលវិទ្យាល័យរ៉ាត់ហ្គឺ, សហរដ្ឋអាមេរិក
សាស្ត្រាចារ្យ ចន ឆរឆីអារី, សាកលវិទ្យាល័យ មិកស៊ីហ្គិន, សហរដ្ឋអាមេរិក
សាស្ត្រាចារ្យ ចាយ៉ា រ៉េមជី ណូភ្លាស, សាកលវិទ្យាល័យ ថែមផល, សហរដ្ឋអាមេរិក
សាស្ត្រាចារ្យ រ៉ន ស្លាយ, សាកលវិទ្យាល័យ ស៊ីអារ៉ល, សហរដ្ឋអាមេរិក
សាស្ត្រាចារ្យ ជេមស៍ អេ ថាញណឺ, សាកលវិទ្យាល័យ ខិនស្តេក សហរដ្ឋអាមេរិក

**ប្រភពឯកសារ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
មជ្ឈមណ្ឌលសោតទស្សន៍ បុប្ផាណា
នាយកដ្ឋានផ្លូវដែក ក្រសួងសាធារណការ និងដឹកជញ្ជូន
បណ្ណសារដ្ឋានជាតិកម្ពុជា
វិចិត្រសាលសិល្បៈ អាសាសាស្ត្រ
ទូរទស្សន៍ជាតិកម្ពុជា

**រចនា**
ឆាំង យុ
អ៊ីវ៉ុន វុង

**សហការជាមួយ**
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃរបបខ្មែរក្រហម
សារមន្ទីរជាតិកម្ពុជា
មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ តាកែវ និងព្រះសីហនុ
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**ទីប្រឹក្សា**
លោកមេធាវី គ្រីសស្តូហ្វឺ ឌៀរីង
លោកស្រីមេធាវី អេលីហ្សាបេត ស៊ីមុននូ ហ្វត
លោកមេធាវី ពេជ អង្គ
លោកមេធាវី ម៉ាឌៀរ ម៉ូហាន់

**ឧបត្ថម្ភដោយ**
កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ តាមរយៈអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក

រូបថតក្របមុខ : រូប អៀង សារី ជាមួយនឹងគណៈប្រតិភូចិន ចុះត្រួតពិនិត្យការដ្ឋានផ្លូវដែក នៅក្នុងអំឡុងពេលជម្លៀសប្រជាជនដោយបង្ខំនៅចុងឆ្នាំ១៩៧៥។

រក្សាសិទ្ធិគ្រប់យ៉ាងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា
ឆ្នាំ២០១៤
បោះពុម្ពនៅកម្ពុជា
ISBN: 9-789995-060275

## សាលក្រមសំណុំរឿង០០២ ដំណាក់កាលទី១ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៧ ដោយសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយបានរៀបចំផែនការ ញុះញង់ និងជួយជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចជា ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលលើអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់។

បន្ថែមពីលើការរកឃើញខាងលើ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញទៀតថា នួន ជា គឺជាអ្នកដែលបានបញ្ជាចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាល ទី១ និងទី២ ព្រមទាំងការសម្លាប់នៅទួលពោធិ៍ជ្រៃ។

ផ្អែកទៅលើវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំអង្គជំនុំជម្រះឲ្យទទួលស្គាល់គម្រោងសំណងជាក់លាក់សម្រាប់ជនរងគ្រោះ។ គម្រោងសំណងទាំងអស់នោះត្រូវរៀបចំ ដែលមានការសម្របសម្រួលពីអង្គភាពគាំពារជនរងគ្រោះ ដើម្បីទទួលស្គាល់ការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងដោយសារឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ និងដើម្បីផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ។

ពិព័រណ៍អចិន្ត្រៃយ៍ស្តីពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងគម្រោងអប់រំ ការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា (ដែលត្រូវដាក់បញ្ចូលក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ) គឺ ជាគម្រោងសំណងក្នុងចំណោមគម្រោងសំណងសក្តានុពលផ្សេងៗទៀត ដែលបានដាក់ជូនអង្គជំនុំជម្រះ ។ ដោយទទួលស្គាល់ថាគម្រោងសំណងដែលដាក់ជូននេះសមស្របទៅនឹងលក្ខខណ្ឌក្នុងវិធានផ្ទៃក្នុង អង្គជំនុំជម្រះក៏បានទទួលស្គាល់គម្រោងសំណងទាំងនេះនៅក្នុងសំណងតាមផ្លូវច្បាប់នៃសំណុំរឿង០០២ ដំណាក់កាលទី១។

ដោយផ្អែកទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគ្រប់ភាគីទាំងអស់អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការកំណត់អំពីភាពមានទោស ឬគ្មានទោសរបស់ជនជាប់ចោទ នួន ជា និងខៀវ សំផន ក៏ដូចជាអំពីការទទួលស្គាល់ចំពោះសំណងក្នុងសំណុំរឿង០០២ ដំណាក់កាលទី១។



លោកមេឃុំ អ៊ួន វី កំពុងណែនាំក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់អ្នកភូមិដែលបានចូលរួម នៅក្នុងកម្មវិធីការផ្សាយបន្តផ្ទាល់ស្តីពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១ ដែលបានធ្វើ នៅវត្តគូ ស្ថិតក្នុងភូមិគូ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ រូបថត អ៊ិច មករា

# មាតិកា

អារម្ភកថា . . . . . . . . . . ៦
ថ្ងៃទី១៧ ខែមេសា : ការជម្លៀសប្រជាជនដោយបង្ខំ . . . . . . . . . . ៧
ពិព័រណ៍ : ពិព័រណ៍តាមបណ្តាខេត្ត-ក្រុងស្តីពីការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម . . . . . . . . . . ៩
ស្ថានីយរថភ្លើងមោងឫស្សី : រឿងរ៉ាវរបស់ អ៊ុំ សុខា . . . . . . . . . . ១៤
រឿងរ៉ាវជនរងគ្រោះនៅខេត្តពោធិ៍សាត់ : សួន សៀង . . . . . . . . . . ១៥
ស្ថានីយរថភ្លើងស៊ីសុផុន : រឿងរ៉ាវរបស់ ហង្ស ប៉ូលីន . . . . . . . . . . ១៦
រឿងរ៉ាវជនរងគ្រោះមកពីខេត្តកំពង់ធំ : ឡេង យន់ . . . . . . . . . . ១៧
ប្រវត្តិភូមិអូរដំបង ខេត្តបាត់ដំបង : ប៊ី ប៉េង . . . . . . . . . . ១៩
រឿងរ៉ាវពីខេត្តស្វាយរៀង : វ៉ាន់ សន . . . . . . . . . . ២១
បូជនីយដ្ឋាន រណ្តៅសាកសព និងគុក នៅស្រុកបាទី ខេត្តតាកែវ . . . . . . . . . . ២២
រឿងព្រេងនិទានខ្មែរ . . . . . . . . . . ២៤
ការស្លាប់នៅក្នុងចលនានៃការជម្លៀសដោយបង្ខំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ . . . . . . . . . . ២៦
តើអ្នកអាចជួយព្យាបាលរបួសនៅក្នុងសង្គមកម្ពុជាឱ្យជាសះស្បើយតាមវិធីណា? . . . . . . . . . . ២៨
ការចងចាំនៃការជម្លៀសដោយបង្ខំ . . . . . . . . . . ៣០
រូបថត . . . . . . . . . . ៣៤

# អារម្ភកថា



នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សម្បត្តិវប្បធម៌ជាតិជាច្រើននៅក្នុងប្រទេសកម្ពុជាបានទទួលរងការបំផ្លិចបំផ្លាញ។ តន្ត្រី សិល្បៈ សាសនា ប្រពៃណី ទំនៀមទម្លាប់ ត្រូវបំផ្លិចបំផ្លាញក្រោមការដឹកនាំរបបមួយ ដែលគ្មានមនុស្សធម៌ និងភាពជាមនុស្សនៅក្នុងខ្លួន។

កូនព្រាត់ម្ដាយ ប្ដីព្រាត់ប្រពន្ធ គ្រួសារទាំងមូលត្រូវបែកបាក់។ ទីក្រុង និងទីប្រជុំជនទាំងឡាយក្លាយទៅជាទីរហោស្ថាន។ ប្រជាជនទូទាំងប្រទេសកម្ពុជាត្រូវបង្ខំឲ្យធ្វើដំណើរដោយថ្មើរជើង និងមិនមានរបស់របរជាប់ខ្លួន។ មនុស្សរាប់លាននាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។

នេះសបញ្ជាក់ឲ្យឃើញថា របបនេះមិនត្រឹមតែបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើមនុស្សជាតិទេ តែក៏បានប្រល័យលើវប្បធម៌របស់ខ្លួនឲ្យស្ទើរវិនាសសាបសូន្យដែរ។

ការតាំងពិព័រណ៍ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម គឺជាកិច្ចការដ៏សំខាន់មួយដែលនឹងរួមចំណែកដោះស្រាយបញ្ហានេះ និងផ្ដល់ជាប្រយោជន៍ជាច្រើនដល់សង្គមរបស់យើង។ ប្រសិនបើប្រទេសមួយមិនបានរៀនសូត្រ ព្រមទាំងដោះស្រាយវិបត្តិដែលបន្សល់ទុកពីអតីតកាលនោះទេ ប្រទេសនោះនឹងអាចដើរជាន់លើដានចាស់ ពុំមានលទ្ធភាព និងសេចក្ដីក្លាហានក្នុងការប្រឈមមុខជាមួយឧបសគ្គ នាពេលបច្ចុប្បន្ន និងអនាគតនោះបានឡើយ។

ឧបសគ្គ និងវិបត្តិជាច្រើន ដែលយើងទាំងអស់គ្នាកំពុងតែប្រឈមមុខ គឺជាកេរដំណែលនៃប្រវត្តិសាស្ត្ររបស់យើង។ យើងទាំងអស់គ្នាត្រូវតែហ៊ានទទួលខុសត្រូវ និងធ្វើការសិក្សាស្រាវជ្រាវនូវប្រវត្តិសាស្ត្រដ៏ជូរចត់នេះ សម្រាប់បង្រៀនសង្គមជាតិ ក្មេងជំនាន់ក្រោយ និងពិភពលោកទាំងមូល។ ក៏ប៉ុន្តែការសិក្សាប្រវត្តិសាស្ត្រមិនមែនត្រឹមមានន័យថា យើងសិក្សាអំពីវិបត្តិដែលកើតឡើងក្នុងអតីតកាល ដើម្បីយកមកដោះស្រាយវិបត្តិនាពេលបច្ចុប្បន្ននោះទេ។ នៅពេលដែលយើងសិក្សាប្រវត្តិសាស្ត្រ យើងត្រូវចងចាំថា សាច់រឿងមួយឆ្លុះបញ្ចាំងពីបទពិសោធន៍របស់មនុស្សម្នាក់។ ទស្សនៈនេះមានប្រយោជន៍មិនត្រឹមតែសម្រាប់តែបុគ្គលម្នាក់ៗនោះទេ ប៉ុន្តែគឺសម្រាប់សង្គមជាតិទាំងមូល។ ប្រជាជនដែលរងគ្រោះដោយអំពើយង់ឃ្នងក្នុងរបបខ្មែរក្រហម គប្បីសមនឹងទទួលបានការគោរព និងការចងចាំ។ តាមរយៈការសិក្សាអំពីសាច់រឿងរបស់បុគ្គលម្នាក់ៗនៅក្នុងពិព័រណ៍ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម យើងទាំងអស់គ្នាមិនត្រឹមតែផ្ដល់ការគោរពចំពោះបុគ្គលម្នាក់ៗនោះទេ តែជាការគោរពដល់សិទ្ធិរបស់ប្រជាជនទូទៅ។

តាមរយៈសាច់រឿងរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម យើងនឹងយល់អំពីតម្លៃ និងស្មារតីតស៊ូរបស់ជនរងគ្រោះ ដែលបានឆ្លងកាត់ទុក្ខវេទនាដ៏សែនឈឺចាប់ និងអំពើសាហាវយង់ឃ្នងដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ វប្បធម៌ជាតិមួយអាចនឹងរលត់បានយ៉ាងងាយ ប្រសិនបើប្រជាជននៅក្នុងសង្គមនោះមិនយល់ដឹងអំពីប្រវត្តិសាស្ត្រ និងវប្បធម៌របស់ខ្លួន។ ជាក់ស្ដែង សម្បត្តិវប្បធម៌ជាតិអាចទទួលរងការបំផ្លិចបំផ្លាញបានយ៉ាងងាយ មិនថានៅពេលប្រទេសស្ថិតក្នុងភ្លើងសង្គ្រាម ឬមានសន្តិភាពនោះទេ។ ការលួចប្លន់ និងការជួញដូរវត្ថុបុរាណជាទម្រង់នៃការបំផ្លាញសម្បត្តិវប្បធម៌ជាតិដ៏ធ្ងន់ធ្ងររួចទៅហើយ ប៉ុន្តែបើយើងនៅតែមិនយល់ដឹង និងមិនចាប់អារម្មណ៍ពីសម្បត្តិវប្បធម៌ នោះគុណវិបត្តិនឹងរឹតតែគ្រោះថ្នាក់ជាងនេះទៅទៀត។

ប្រជាជនគ្រប់ជំនាន់ មានតួនាទីថែរក្សា ការពារ និងស្ដារវប្បធម៌ដ៏សម្បូរបែបរបស់ជាតិយើង តាមរយៈការសិក្សាឲ្យបានច្បាស់លាស់ពីវប្បធម៌ និងប្រវត្តិសាស្ត្រ។ គម្រោងតាំងពិព័រណ៍ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម នេះគឺជាការបោះជំហានឆ្ពោះទៅមុខដ៏សំខាន់មួយ ដើម្បីឆ្លើយតបនឹងការថែរក្សា ការពារនិងស្ដារវប្បធម៌ដ៏សម្បូរបែបរបស់ជាតិយើង។




ភឿង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

# ថ្ងៃទី១៧ ខែមេសា ៖ ការជម្លៀសប្រជាជនដោយបង្ខំ

ដោយ ស៊ីរិ សារីណា

ក្រុមគ្រួសាររបស់ខ្ញុំត្រូវបង្ខំឱ្យចេញពីផ្ទះនៅទីក្រុងភ្នំពេញ ទៅស្រុកកំណើតនៅឯខេត្តព្រៃវែងដែលជាខេត្តមួយនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ ស្ថិតនៅក្នុងស្ថានភាពភ័យខ្លាច និងច្របូកច្របល់ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរជាមួយនឹងអ្នកជម្លៀសផ្សេងទៀត ឆ្លងកាត់មហាវិថីព្រះមុន្នីវង្ស ឆ្ពោះទៅផ្លូវជាតិលេខ១ ដើម្បីទៅដល់គោលដៅរបស់ខ្លួន។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើង ដោយមានចងភ្ជាប់របស់របរមួយចំនួនទៅនឹងម៉ូតូ។ នៅពេលយប់ យើងត្រូវសម្រាកនៅតាមផ្លូវនៅកន្លែងដែលយើងដើរទៅដល់។ ម្តាយរបស់ខ្ញុំបានរំឭកថា នៅល្ងាចមួយ គ្រួសាររបស់ខ្ញុំបានដេកលើសាកសពប្រជាជនដទៃទៀត ដែលត្រូវសម្លាប់នៅក្នុងអំឡុងពេលធ្វើដំណើរដោយពុំបានដឹងខ្លួនសោះ។

ក្រុមគ្រួសាររបស់ខ្ញុំមិនបានធ្វើដំណើរទៅដល់ខេត្តព្រៃវែងនោះទេ ហើយបានប្តូរទិសដៅទៅខេត្តកំពង់ចាមដែលសាច់ញាតិម្តាយរបស់ខ្ញុំរស់នៅវិញ។ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅខេត្តកំពង់ចាមរហូតរបបខ្មែរក្រហមត្រូវបានដួលរំលំ។ ក្នុងនាមជា "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧មេសា" ក្រុមគ្រួសាររបស់ខ្ញុំតម្រូវឱ្យរស់នៅលាយឡំជាមួយ "ប្រជាជនមូលដ្ឋាន" ដែលខ្មែរក្រហមចាត់ទុកជាប្រជាជនដែលអាចជឿទុកចិត្តបាន។ ក្រោយមកក្រុមគ្រួសាររបស់ខ្ញុំ ត្រូវជម្លៀសទៅរស់នៅក្នុងសហករណ៍មួយដែលជាកន្លែងធ្វើការងារ និងហូបបាយរួម។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវចាត់ចែងឱ្យធ្វើស្រែ និងប្រមូលជ័រកៅស៊ូ។ ឪពុកម្តាយរបស់ខ្ញុំ ត្រូវបំបែកឱ្យរស់នៅកងផ្សេងគ្នា។ ចំណែកឯបងប្រុសរបស់ខ្ញុំចំនួនពីរនាក់ ម្នាក់អាយុ៤ឆ្នាំ និងម្នាក់ទៀតអាយុ៧ឆ្នាំ តម្រូវឱ្យរស់នៅក្នុងកងកុមារ។ ដោយសារឪពុករបស់ខ្ញុំជាអ្នកទីក្រុង និងជាគ្រូបង្រៀននៅសង្គមចាស់ ជីវិតរបស់ឪពុកខ្ញុំជួបការលំបាក។ គាត់មិនសូវដឹងពីរបៀបធ្វើស្រែនោះទេ។ ឪពុករបស់ខ្ញុំបានរួចជីវិតដោយសារតែការជួយការពារពីសំណាក់ក្រុមគ្រួសាររបស់ម្តាយខ្ញុំដែលជា"ប្រជាជនមូលដ្ឋាន"។ ជាសំណាងអាក្រក់ សមាជិកដទៃទៀតនៅក្នុងក្រុមគ្រួសារខ្ញុំដែលបានជម្លៀសទៅភូមិភាគនិរតីនៅក្នុងខេត្តកំពតបានស្លាប់បាត់បង់ជីវិត ដោយសារតែស្ថានភាពរស់នៅលំបាក និងការសម្លាប់។ រយៈពេលជាង៣០ឆ្នាំបានកន្លងផុតទៅ ឪពុករបស់ខ្ញុំនៅតែរក្សាភាពស្ងៀមស្ងាត់ ចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ បើទោះបីជាឪពុករបស់ខ្ញុំមិនបាននិយាយប្រាប់ខ្ញុំ អំពីជីវិតរបស់គាត់នៅរបបខ្មែរក្រហមក៏ដោយ ក៏អំពើហិង្សា និងរឿងរ៉ាវ ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានជះឥទ្ធិពលទៅលើគ្រួសាររបស់ខ្ញុំ និងសង្គមកម្ពុជា។

ទិដ្ឋភាពរបស់ប្រទេសកម្ពុជា បានបញ្ជាក់នូវអំពើហិង្សា ដែលធ្លាប់កើតឡើង។ ប្រទេសកម្ពុជាបានជួបប្រទះនូវសង្គ្រាមស៊ីវិលអស់រយៈពេលជិត៥ឆ្នាំ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥។ បន្ទាប់មក កម្ពុជាក៏បានធ្លាក់ចូលទៅក្នុងកណ្តាប់ដៃបដិវត្តន៍ខ្មែរក្រហមដែលកាន់កាប់ប្រទេសកម្ពុជា ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ កម្ពុជាប្រជាធិបតេយ្យ គឺជាឈ្មោះជាផ្លូវការរបស់ខ្មែរក្រហម។ ខ្មែរក្រហមបានបង្កើតគោលនយោបាយ និងការអនុវត្តថ្មីៗដែលបង្កប់ទៅដោយភាពហិង្សា។ ប្រជាជនក្នុងទីក្រុងជាច្រើនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទៅតាមសហករណ៍នៅតាមទីជនបទ។

នៅមុនពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ចំនួនប្រជាជននៅទីក្រុងបានកើនឡើងដល់ជាច្រើនលាននាក់ក្នុងរយៈពេលតែ៥ឆ្នាំប៉ុណ្ណោះ។ ការកើនឡើងនៃចំនួនប្រជាជននៅទីក្រុងភ្នំពេញ ដោយសារតែជនភៀសខ្លួនពីខេត្តដាច់ស្រយាលមករស់នៅទីក្រុង ដើម្បីគេចផុតពីជម្លោះប្រដាប់អាវុធ ការទម្លាក់គ្រាប់បែក និងការកេណ្ឌទ័ពរបស់ខ្មែរក្រហម។ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទីក្រុងទាំងអស់ឱ្យត្រឡប់ទៅស្រុកកំណើតវិញ។ ភាពច្របូកច្របល់ និងភាពភ័យខ្លាច ប្រជាជនត្រូវជម្លៀសទៅកាន់តំបន់ផ្សេងៗ ក្រោមការឃ្លាំមើលរបស់កងទ័ពខ្មែរក្រហម។

ការជម្លៀសប្រជាជនចេញពីទីក្រុង បានបង្ហាញពីសោកនាដកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ខ្មែរក្រហមបានបង្ខំប្រជាជនទីក្រុងឱ្យធ្វើការជាទម្ងន់នៅតាមទីជនបទ រស់នៅក្នុងសហករណ៍រួម និងត្រូវបានចាត់ចែងឱ្យធ្វើការនៅក្នុងគម្រោងកសិកម្ម និងប្រព័ន្ធធារាសាស្ត្រដ៏ធំ។ ដើម្បីគ្រប់គ្រងប្រជាជន និងការផលិតរបស់ខ្លួន

ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខ និងជំរំការងារពាសពេញប្រទេស។ មន្ទីរពេទ្យ សាលារៀន វត្តអារាម និងវិហារសាសនា ត្រូវបានបិទ និងប្រែក្លាយទៅជាឃ្លាំង ឬគុក។ ការប្រណិប័តន៍សាសនា និងប្រាក់កាសត្រូវបានហាមឃាត់។ មិនតែប៉ុណ្ណោះ ខ្មែរក្រហម មិនអនុញ្ញាតឱ្យប្រតិបត្តិវប្បធម៌របស់របបមុន ក៏ដូចជាជីវិតគ្រួសារ និងការនិយាយ ភាសា។ ការប៉ុនប៉ងរបស់ខ្មែរក្រហមក្នុងការកសាងប្រទេសឡើងវិញ ដោយឈរលើ មនោគមវិជ្ជារបស់ខ្លួនបានបង្កជាអំពើហិង្សា និងភាពភ័យខ្លាច។ ជាលទ្ធផល សោកនាដ កម្ម ទាំងនោះបានដក់ជាប់នៅក្នុងសង្គមកម្ពុជាអស់ជាច្រើនទសវត្សរ៍។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាត្រូវផ្លាស់ប្តូរទីលំនៅជាបន្តបន្ទាប់ ពីកន្លែង មួយទៅកន្លែងមួយទៀត ដូចជាពីខេត្តកំពង់ចាម តាកែវ កណ្តាល និងព្រៃវែង ទៅខេត្ត ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តផ្សេងៗទៀត។ ជាការសន្និដ្ឋាន ខ្មែរក្រហម ជម្លៀសប្រជាជនពីទិសអាគ្នេយ៍ ទៅទិសពាយ័ព្យនៃប្រទេសកម្ពុជា។ ប្រជាជនតម្រូវឱ្យធ្វើ ដំណើរដោយថ្មើរជើង ឬតាមទូក រថយន្តដឹកទំនិញ រថភ្លើង និងរទេះគោជាដើម។ ប្រជា ជនដែលត្រូវខ្មែរក្រហមជម្លៀស ជួបប្រទះនូវភាពភ័យខ្លាច ភាពច្របូកច្របល់ និងការប៉ះ ទង្គិចផ្នែកផ្លូវចិត្ត ដោយសារតែទទួលរងនូវភាពស្រេកឃ្លាន ការបំបែកចេញពីគ្រួសារ និង ការបង្ខំឱ្យធ្វើដំណើរដោយមិនដឹងពីគោលដៅច្បាស់លាស់។ ជាពិសេស គឺការជម្លៀស តាមរថភ្លើង។ ប្រជាជននៅលើទូរថភ្លើងពុំមានអាហារសម្រាប់បរិភោគនោះទេ មិនតែ ប៉ុណ្ណោះ អ្នកដំណើរនៅលើទូរថភ្លើងត្រូវបំបែកចេញពីក្រុមគ្រួសារនៅពេលដែលរថភ្លើង ឈប់នៅតាមស្ថានីយនីមួយៗ។ ភាពឈឺចាប់នៃការបាត់បង់ និងការរងរបួសផ្នែកផ្លូវចិត្ត របស់ប្រជាពលរដ្ឋកម្ពុជា បានបង្ហាញពីការប្រព្រឹត្តិដោយហិង្សារបស់ខ្មែរក្រហម។

ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំ ដែលស្ថិតក្រោមកិច្ចសហ ប្រតិបត្តិការរវាង មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានឆ្លុះបញ្ចាំងពីរឿងរ៉ាវរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតអំពីការជម្លៀស និង ស្ថានភាពរស់នៅដ៏លំបាកនៅក្នុងរបបខ្មែរក្រហម ក៏ដូចជាការចងចាំរបស់អតីតកងទ័ព ខ្មែរក្រហម ដែលបានចូលរួមក្នុងការជម្លៀសប្រជាជន។ តាមរយៈរូបថត រឿងរ៉ាវរបស់អ្នក ដែលនៅរស់រានមានជីវិត ផែនទី និងរឿងរ៉ាវរបស់ជនរងគ្រោះ ដែលមាននៅក្នុងពិព័រណ៍ អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំ នឹងនាំមកនូវការចងចាំ ការទទួលស្គាល់ និង ការគោរពដល់ជនរងគ្រោះ ដែលធ្លាប់ទទួលរងទុក្ខវេទនាក្នុងរបបខ្មែរក្រហម។ កម្មវិធី អប់រំដែលរួមបញ្ចូលជាមួយនឹងការតាំងពិព័រណ៍ នឹងចាប់ផ្តើមនៅសារមន្ទីរខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ព្រះសីហនុ និងតាកែវ។ កម្មវិធីអប់រំនេះនឹងជួយជំរុញឱ្យមាន ការពិភាក្សារវាងប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ ក្រោយ អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងកេរដំណែលដែលខ្មែរក្រហមបានបន្សល់ទុក។ ការអប់រំនេះនឹងធ្វើឡើងនៅតាមទីសាធារណៈ ទីឯកជន សារមន្ទីរខេត្ត សាលារៀន ផ្ទះ និងទីតាំងជាក់លាក់មួយចំនួន ដែលខ្មែរក្រហមបានប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងប្រជា ជនរបស់ខ្លួន។ យើងសង្ឃឹមថាពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំ នឹងធ្វើឱ្យ អ្នកទស្សនាបានឃើញនូវការឈឺចាប់ និងការភ័យខ្លាចដែលមានវត្តមាននៅក្នុងរបបខ្មែរ ក្រហម។

ក្នុងនាមជាក្មេងជំនាន់ក្រោយ ដែលកើតក្រោយរបបដ៏គួរឱ្យតក់ស្លុត រូបភាពនៃការ ជម្លៀស និងស្ថានភាពរស់នៅជាប្រចាំថ្ងៃរបស់គ្រួសារខ្ញុំនៅក្នុងរបបខ្មែរក្រហម បានត្រឹម តែស្ថិតនៅក្នុងការស្រមើស្រមៃរបស់ខ្ញុំតែប៉ុណ្ណោះ។ ឪពុករបស់ខ្ញុំមិនដែលទម្លាយរឿងរ៉ាវ ទាំងនោះឱ្យខ្ញុំបានដឹងនោះទេ។ ភាពស្ងៀមស្ងាត់របស់ឪពុកខ្ញុំ មិនបានពន្យល់ខ្ញុំឱ្យបាន ដឹងអំពីរឿងរ៉ាវដែលគាត់ធ្លាប់ឆ្លងកាត់នោះឡើយ។ ប៉ុន្តែភាពស្ងៀមស្ងាត់របស់ឪពុកខ្ញុំ អាចបង្ហាញឱ្យខ្ញុំដឹងអំពីទំហំនៃការឈឺចាប់របស់គាត់នៅក្នុងរបបខ្មែរក្រហម។

ខ្ញុំមានក្តីសង្ឃឹមថា រូបថត និងរឿងរ៉ាវដែលមានក្នុងពិព័រណ៍ នឹងជំរុញឱ្យប្រជាជន កម្ពុជាឱ្យចេះចែករំលែកនូវការចងចាំ និងរៀនសូត្របន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរ ក្រហម។ រឿងរ៉ាវរបស់មនុស្សម្នាក់ៗ គឺជាផ្នែកតូចមួយនៃរឿងរ៉ាវដែលបានកើតឡើង នៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម។ ការប្រមូលផ្តុំរឿងរ៉ាវរបស់ប្រជាជនម្នាក់ៗ អាចធ្វើឱ្យយើងបានយល់ដឹងបន្ថែមអំពីព្រឹត្តិការណ៍ ដែលបានកើតឡើងមកលើគ្រួសារ របស់យើង និងគ្រួសារដទៃទៀតនៅទូទាំងប្រទេសកម្ពុជា។ ផលប៉ះពាល់នៃអំពើហិង្សា ដែលបានកើតឡើងត្រូវបានដឹងឮដោយអ្នកនៅជុំវិញខ្លួន និង ជួយជំរុញ ឱ្យមានការជួសជុលឡើងវិញនូវភាពថ្លៃថ្នូរជាមនុស្ស ដល់ជនដែលនៅរស់រានមានជីវិត ពីអំពើប្រល័យពូជសាសន៍។



ស៊ីវ៉ិ សាវីណា
ប្រធានសារមន្ទីរនៃការចងចាំ
វិទ្យាស្ថានស្លឹករឹត

## ប្រវត្តិសង្ខេប

ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ២៥ភាគរយ បានស្លាប់ដោយសារការសម្លាប់ ការអត់ឃ្លាន និងជំងឺ នៅក្នុងរបបខ្មែរក្រហម ដែលមានឈ្មោះជាផ្លូវការថា របបកម្ពុជាប្រជាធិបតេយ្យ។ នៅខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិដែលបានកើតឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ដោយផ្អែកលើកិច្ចព្រមព្រៀងនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវបង្កើតឡើងនៅក្នុងប្រព័ន្ធតុលាការកម្ពុជា និងបានចាប់ផ្តើមដំណើរការនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦។

ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ៤០០០នាក់ និងអ្នកដាក់ពាក្យបណ្តឹង ចំនួន ៦០០០នាក់ បានចូលរួមក្នុងដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក្នុងបំណងចូលរួមផ្តល់សក្ខីកម្ម និងស្វែងរកយុត្តិធម៌ជូនសាច់ញាតិដែលបានស្លាប់ និងរងគ្រោះនៅក្នុងរបបខ្មែរក្រហម។ យ៉ាងណាមិញ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសារមានឱកាសបញ្ចេញសំឡេង និងមតិយោបល់នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រមទាំងបង្កើតឱ្យមានសកម្មភាពផ្សេងៗទៀត ដូចជាការចែករំលែករឿងរ៉ាវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយ។

នាពេលបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាប្រមាណ៧០ភាគរយ ដែលបានកើតក្រោយឆ្នាំ១៩៧៩ កំពុងស្ថិតនៅត្រង់ចំណុចរបត់សំខាន់មួយក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ នៅពេលដែលដំណើរការស្វែងរកការពិត យុត្តិធម៌ និងការផ្សះផ្សា ដើរតួនាទីយ៉ាងសំខាន់សម្រាប់ការកសាងសង្គមក្រោយជម្លោះ នឹងក្លាយជាសង្គមមួយដែលមានអារ្យធម៌ឡើងវិញ ការអប់រំ ការចងចាំ និងការចូលរួមពិភាក្សារបស់ប្រជាពលរដ្ឋអំពីអតីតកាល គឺជាកត្តាដ៏ចាំបាច់សម្រាប់អនាគតរបស់ប្រទេសជាតិ។ ក្រោយពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបញ្ចប់ ការរៀនសូត្រពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាកត្តាសំខាន់ដែលត្រូវធ្វើ ដោយសារតែរឿងរ៉ាវទាំងនេះ មិនត្រឹមតែមានតម្លៃសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាប៉ុណ្ណោះទេ ថែមទាំងជួយជំរុញដល់ការអប់រំយុវជនជំនាន់ក្រោយថែមទៀត។

## ការជម្លៀសដោយបង្ខំ

ចន្លោះឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ ប្រជាជនបានភៀសខ្លួនរត់មកជ្រកកោននៅទីក្រុងភ្នំពេញ ដើម្បីជៀសផុតពីសង្គ្រាមរវាងកងទ័ព លន់ នល់ និងខ្មែរក្រហម។ ជាលទ្ធផល ចំនួនប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័សរហូតដល់រាប់លាននាក់នៅទីក្រុងភ្នំពេញ។

កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយចាប់ផ្តើមប្រើពាក្យ "ជម្លៀស" ដែលបន្ទាប់មកប្រើពាក្យ "ជម្លៀសដោយបង្ខំ"។ នៅពេលនោះហើយ ទីក្រុងភ្នំពេញបានប្រែក្លាយជាទីក្រុងដ៏ស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ។ បុរសស្ត្រីគ្រប់ស្រទាប់វណ្ណៈ មនុស្សចាស់ កុមារាកុមារី ព្រះសង្ឃ និងដូនជី ព្រមទាំងសាសនិកជនដទៃទៀត អ្នកជំងឺព្យាបាលនៅមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ ឬស្ត្រីដែលទើបនឹងសម្រាលកូនរួច ត្រូវបង្ខំឱ្យចាកចេញពីទីក្រុង។ ប្រជាជនជាច្រើនត្រូវបង្ខំឱ្យចាកចេញដោយថ្មើរជើងឆ្ពោះទៅកាន់ផ្លូវជាតិនានាគ្រប់ទិសទី ជើង ត្បូង លិច កើត។ ប្រជាជនបានធ្វើដំណើរទៅមុខដោយមិនបានដឹងពីគោលដៅច្បាស់លាស់ ហើយភាគច្រើនត្រូវប្រាប់ថា ឱ្យទៅនៅស្រុកកំណើតរបស់ខ្លួនវិញ។ ប្រជាជនដែលជម្លៀសមកពីក្រុងភ្នំពេញត្រូវសម្គាល់ថាជា "ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" នៅពេលដែល "ប្រជាជនមូលដ្ឋាន" ត្រូវចាត់ទុកថា ជាមនុស្សគួរឱ្យទុកចិត្តបាន និងស្មោះត្រង់ជាមួយអង្គការបដិវត្តន៍។ ប្រជាជនដែលជាប់ពាក់ព័ន្ធនឹងជីវិតអ្នកទីក្រុងបស្ចិមប្រទេស ឬសម្បូរទ្រព្យធនត្រូវរើសអើង។ កងទ័ពខ្មែរក្រហម ដែលស្លៀកពាក់ខោអាវខ្មៅ ឬពណ៌អាចម៍សេះ បង់កក្រមា បានបង្ខំប្រជាជនឱ្យធ្វើដំណើរទៅមុខ ហើយពេលខ្លះបានគំរាមកំហែងវាយដំ និងប្លន់យកទ្រព្យសម្បត្តិពីប្រជាជនក្នុងពេលជម្លៀស។ ប្រជាជនត្រូវដេកសម្រាកនៅតាម

ដងផ្លូវ និងក្រោមដើមឈើ ហើយហូបតែបាយបន្តិចបន្តួច។ ដោយសារការធ្វើដំណើរផ្លូវឆ្ងាយ ប្រជាជនដែលត្រូវជម្លៀសបានជួបប្រទះការខ្វះខាតយ៉ាងច្រើនដែលបង្កឱ្យមានការហេវហត់ កើតជំងឺហើមដៃជើង និងរាគ។ ជាសរុប ប្រជាជនចំនួនប្រមាណ២លាននាក់ ត្រូវជម្លៀសដោយបង្ខំឱ្យចាកចេញពីទីក្រុង។ ប្រជាជនប្រហែល៣០០០នាក់បានស្លាប់ក្នុងពេលជម្លៀស។

ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ប្រជាជនមួយចំនួនធំត្រូវជម្លៀសចេញពីភូមិភាគកណ្តាល និងភូមិភាគនិរតីនៃប្រទេស រួមមានខេត្តកណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម ឆ្ពោះទៅកាន់ខេត្តសៀមរាប ព្រះវិហារ និងភូមិភាគពាយ័ព្យ រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ។

នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារដែលបានបន្សល់ទុកពីរបបខ្មែរក្រហមបង្ហាញឱ្យដឹងថា ប្រជាជនប្រមាណពី៤សែនទៅ៥សែននាក់ ត្រូវខ្មែរក្រហមបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ ហើយប្រជាជនចំនួនប្រមាណ៥ម៉ឺននាក់ផ្សេងទៀតត្រូវជម្លៀសចេញពីភូមិភាគបូព៌ា រួមមាន ខេត្តព្រៃវែង និងស្វាយរៀង។

បុគ្គលិកធ្វើការនៅស្ថានីយរថភ្លើង ពិតជាបានឃើញប្រជាជនរាប់ម៉ឺននាក់ ត្រូវជម្លៀសតាមខ្សែរថភ្លើងចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ស្ថានីយរថភ្លើងផ្សេងៗ ដូចជាខេត្តពោធិ៍សាត់ និងបាត់ដំបង នៃភូមិភាគពាយ័ព្យ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវជម្លៀសពីកន្លែងមួយទៅកាន់កន្លែងមួយតាមមធ្យោបាយផ្សេងៗ ដូចជា រថភ្លើង រថយន្តឯកជន រថយន្តទាហាន ទូក កាណូត រទេះគោ ត្រាក់ទ័រ និងថ្មើរជើង។ ដោយឡែក ការជម្លៀសប្រជាជនទៅកាន់ភូមិភាគពាយ័ព្យត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំតាមរយៈរថភ្លើង ដែលក្នុងទូរថភ្លើងនីមួយៗមានមនុស្សចំនួន១០០នាក់ឈរប្រជ្រៀតគ្នាណែនណាន់តាន់តាប់ ហើយពុំមានអាហារ ឬទឹកបរិភោគគ្រប់គ្រាន់។ កងទ័ពខ្មែរក្រហម គឺជាអ្នកមើលការខុសត្រូវក្នុងការជម្លៀសប្រជាជននិងមានភារកិច្ចត្រួតពិនិត្យប្រជាជនជម្លៀសតាមរថភ្លើង ទូក និងរទេះគោ ហើយចាំទទួលប្រជាជនជម្លៀសនៅតាមចំណតស្ថានីយរថភ្លើងនីមួយៗ ទៅកាន់សហករណ៍នានា។

## ការតាំងពិព័រណ៍

ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនចេញពីតំបន់ផ្សេងៗទៅកាន់កន្លែងផ្សេងទៀត ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការខ្មែរក្រហម។ រឿងរ៉ាវដែលកើតឡើងទាំងអស់នេះនឹងរៀបចំតាំងបង្ហាញនៅក្នុងពិព័រណ៍ដែលរៀបចំឡើងដោយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ពិព័រណ៍នេះនឹងដាក់តាំងជាដំបូងនៅសារមន្ទីរខេត្តចំនួន៥ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ព្រះសីហនុ និងតាកែវ។ រឿងរ៉ាវទាក់ទងនឹងការជម្លៀសតាមខ្សែរថភ្លើង ដែលនឹងយកមកដាក់តាំង គឺជារឿងរ៉ាវ ដែលបានមកពីការរៀបរាប់ប្រាប់របស់អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ រឿងរ៉ាវទាំងនោះរៀបរាប់ពីដំណើរដើមទង ចាប់ពីពេលជម្លៀស រហូតដល់ការចុះនៅតាមចំណតស្ថានីយរថភ្លើងនីមួយៗ ឬក៏តាមស្រុកភូមិ និងរឿងរ៉ាវបង្ខំឱ្យធ្វើការនៅតាមសហករណ៍។ ពិព័រណ៍នេះ ក៏មានដាក់តាំងសាច់រឿងរបស់អតីតកងទ័ពខ្មែរក្រហមដែលធ្លាប់ធ្វើការនៅតាមស្ថានីយរថភ្លើង ដែលបានចូលរួមបដិវត្តន៍ និងបានឃើញព្រឹត្តិការណ៍ជម្លៀសប្រជាជនទ្រង់ទ្រាយធំ។ សាច់រឿងរបស់អតីតកងទ័ពខ្មែរក្រហម នឹងបង្ហាញពីការទទួលខុសត្រូវចំពោះការជម្លៀសប្រជាជន។ ស្ថានីយរថភ្លើងនីមួយៗសុទ្ធសឹងតែជាចំណុចដែលបង្ហាញពីពេលវេលា និងទីកន្លែងប្រវត្តិសាស្ត្រ នៃការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហម។

ពិព័រណ៍នេះ នឹងចាប់ផ្តើមដំណើរការ និងសម្ពោធជាលើកដំបូងនៅសារមន្ទីរខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ខេត្តទាំងពីរនេះ មានទីតាំងនៅភូមិភាគពាយ័ព្យនៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍ទាំងពីរកន្លែងនេះមានសារសំខាន់ណាស់ ដោយសារតែប្រជាជនភាគច្រើន ត្រូវជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ។ ពិព័រណ៍ក្រោមប្រធានបទដដែលនេះ នឹងយកទៅដាក់តាំងនៅសារមន្ទីរខេត្តចំនួនបីផ្សេងទៀត នៅខេត្តកំពង់ធំ ព្រះសីហនុ និងតាកែវ។

## ទស្សនវិស័យ

សារមន្ទីរ ជាកន្លែងដែលបង្ហាញពីតម្លៃសង្គម។ ហេតុនេះ សារមន្ទីរទាំងនេះត្រូវតែ

រៀបចំឡើងសម្រាប់អ្នកទស្សនាគ្រប់លំដាក់ថ្នាក់។ ទន្ទឹមនឹងការតាំងពិព័រណ៍នេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំកម្មវិធីសិក្សាអប់រំ ដោយផ្តល់ឱកាសដល់សិស្សានុសិស្ស និងនិស្សិតទៅទស្សនាសារមន្ទីរខេត្តដែលខ្លួនរស់នៅ។ ខិតប័ណ្ណពិព័រណ៍ និងសកម្មភាពអប់រំ នឹងត្រូវបោះពុម្ពផ្សាយដើម្បីធានាថាអ្នកដែលមកទស្សនាអាចទទួលបានព័ត៌មានបន្ថែមសម្រាប់ការសិក្សាត្រិះរិះពិចារណា និងរៀនសូត្របន្ថែមអំពីការចងចាំរបស់ជនរងគ្រោះ និងអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។

ស្របពេលដែលសារមន្ទីរ ជាកន្លែងសិក្សារៀនសូត្រ សម្រាប់អ្នកទស្សនាទាំងឡាយឱ្យចេះត្រិះរិះពិចារណា ពិព័រណ៍នេះក៏ត្រូវរៀបចំឡើង ដើម្បីនាំមកនូវសេចក្តីថ្លៃថ្នូរ និងសេចក្តីស្មោះត្រង់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគ្រប់រូបដែរ។ គោលបំណងសំខាន់នៃការតាំងពិព័រណ៍នេះមិនត្រឹមតែនាំមកនូវភាពយុត្តិធម៌ ដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានប្រឹងប្រែងកន្លងមកប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យសម្រេចបាននូវយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ។

## រឿងរ៉ាវរបស់ជនរងគ្រោះ

លោក អ៊ុង ផល្លី អាយុ៤៨ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើសក្ខីកម្មនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កាលពីខែឧសភា ឆ្នាំ២០១៣។ គាត់បានរំឭកពីការជម្លៀសចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ផល្លី និងក្រុមគ្រួសាររបស់គាត់ បានចំណាយពេល១៥ថ្ងៃ ក្នុងការធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ១ សំដៅទៅកាន់ខេត្តព្រៃវែង។ ក្រោយពីពេលទៅដល់ខេត្តព្រៃវែងមួយរយៈ ឪពុករបស់ ផល្លី ត្រូវខ្មែរក្រហមចាប់យកទៅ។ ចាប់តាំងពីពេលនោះមក ផល្លី មិនដែលបានឃើញមុខឪពុករបស់ខ្លួនម្តងទៀតទេ។ ប្រាំថ្ងៃក្រោយមកទៀត ម្តាយ និងបងប្អូនរបស់ ផល្លី ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់។ មានតែ ផល្លី ជីដូន និងចៅម្នាក់ប៉ុណ្ណោះ ដែលបានរួចរស់ជីវិតពីការជម្លៀសជំហានដំបូងរបស់ខ្មែរក្រហម។ បន្ទាប់មកទៀត ផល្លី និងសាច់ញាតិ ត្រូវខ្មែរក្រហមជម្លៀសបន្តតាមទូកត្រឡប់មកទីក្រុងភ្នំពេញវិញ រួចជម្លៀសបន្តតាមរថភ្លើងទៅកាន់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ មិនយូរប៉ុន្មាន ជីដូន និងចៅដែលជាសាច់ញាតិចុងក្រោយរបស់ ផល្លី បានស្លាប់ ដោយសារតែការបាត់បង់សាច់ញាតិ និងការផ្លាស់ទីលំនៅឥតឈប់ឈរ ការរស់នៅលំបាកវេទនា និងកង្វះអាហារ។ បន្ទាប់ពីចុះពីលើទូរថភ្លើង ផល្លី ត្រូវខ្មែរក្រហមបញ្ជូនឱ្យទៅនៅក្នុងកងកុមារនៅក្នុងស្រុកមោងឫស្សី។

## អតីតកម្មាភិបាលខ្មែរក្រហម ដែលជាអ្នកបើកបររថភ្លើង

នៅក្នុងរបបខ្មែរក្រហម មិនមែនមានតែប្រជាជនថ្មីទេ ដែលត្រូវខ្មែរក្រហមរើសអើង និងធ្វើទុក្ខបុកម្នេញ ប្រជាជនមូលដ្ឋានដែលមានជំនាញ និងមានប្រយោជន៍សម្រាប់ខ្មែរក្រហមក៏ត្រូវខ្មែរក្រហមសម្លាប់ចោលដែរ។ ថាច់ កឹម គឺជាអតីតកម្មាភិបាលបើកបររថភ្លើងមួយរូបរបស់ខ្មែរក្រហម ដែលធ្លាប់ទទួលបានការបណ្តុះបណ្តាលនៅខេត្តបាត់ដំបង ខេត្តកំពង់ធំ និងទីក្រុងភ្នំពេញ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ថាច់ កឹម ត្រូវខ្មែរក្រហមជ្រើសរើសឱ្យធ្វើជាអ្នកបើកបររថភ្លើង និងបង្រៀនកម្មាភិបាលដទៃឱ្យចេះបើកបររថភ្លើង។ ថាច់ កឹម ក៏ត្រូវបានចាត់តាំងឱ្យដឹកជញ្ជូនប្រជាជនតាមរថ-ភ្លើងពីទីក្រុងទៅកាន់ខេត្តបាត់ដំបង ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ប្រជា-ជនរាប់ពាន់នាក់ត្រូវជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ ដើម្បីធ្វើការងារនៅតាមស្រែចម្ការ និងបង្កបង្កើនផលស្រូវ។ ថាច់ កឹម ក៏ធ្លាប់បើករថភ្លើងទៅកាន់ស្ថានីយស្វាយស៊ីសុផន និងប៉ោយប៉ែតដែរ។ ក្នុងរបបខ្មែរក្រហម ថាច់ កឹម បានរក្សាទំនាក់ទំនងជាមួយប្អូនស្រីរបស់ខ្លួនជានិច្ច។ ថាច់ កឹម បានលាក់សំបុត្រនៅក្នុងថង់ផ្លែឈើ និងក្រណាត់ រួចបោះបង្វិចនោះទៅឱ្យប្អូនស្រីរបស់ខ្លួនរៀងរាល់ពេលធ្វើដំណើរឆ្លងកាត់សហករណ៍ ដែលប្អូនស្រីគាត់ធ្វើការ។ នៅឆ្នាំ១៩៧៧ ថាច់ កឹម ត្រូវខ្មែរក្រហមបញ្ជូនទៅកាន់ពេជ្រនិល។ ថាច់ កឹម បានសរសេរសំបុត្រប្រាប់ប្អូនស្រីរបស់ខ្លួនថា ប្រសិនបើមិនបានឃើញគាត់ត្រឡប់មកវិញក្នុងរយៈពេលពី៤ទៅ៥ថ្ងៃទេ មានន័យថាគាត់ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ហើយ។ កម្មាភិបាលខ្មែរក្រហមដទៃទៀត ដែលធ្វើការនៅក្នុងកងរថភ្លើងក៏បានបាត់ខ្លួនដែរ។ ប្អូន-ស្រី និងប្រពន្ធរបស់ ថាច់ កឹម ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម មិនបានដឹងថាមូលហេតុអ្វីបានជាខ្មែរក្រហមជ្រើសរើស ថាច់ កឹម ឱ្យធ្វើការងារ រួចហើយសម្លាប់គាត់ចោលនោះទេ។

ស្ថានីយរថភ្លើងកុមារាជា នៅខេត្តតាកែវ ជាទីចំណតមួយដែលខ្មែរក្រហមជម្លៀសប្រជាជនពីទិសទក្សិណទៅកាន់ទិសឧត្តរ
នៅក្នុងរបបខ្មែរក្រហម។ រូបថត ៖ សេង គន្ធី





# ស្ថានីយរថភ្លើងមោងឫស្សី ៖ រឿងរ៉ាវរបស់ អ៊ំ សុខា

ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ អ៊ំ រន។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច ក្រុមគ្រួសាររបស់ខ្ញុំរស់នៅជុំគ្នាជាធម្មតា។ រហូតដល់ខែតុលា ឆ្នាំ១៩៧៥ កងឈ្លបខ្មែរក្រហម ដែលមិនស្គាល់ឈ្មោះចំនួនបីនាក់ បានមកហៅឪពុករបស់ខ្ញុំ ព្រមទាំងប្រជាជនដែលធ្វើការនៅក្នុងកងជាមួយគាត់ចំនួន១០នាក់ផ្សេងទៀតពីភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល យកទៅរៀនសូត្រ និងក្រោយមកយកទៅដាក់នៅមន្ទីរសន្តិ-សុខទន្លេក្នុង។ មូលហេតុដែលអង្គការចាប់ខ្លួនឪពុកខ្ញុំ ដោយសារតែគាត់ធ្លាប់ធ្វើជាមេស្រុកកាលពីជំនាន់ លន់ នល់។

នៅឆ្នាំ១៩៧៦ ក្រុមគ្រួសារខ្ញុំ ព្រមទាំងអ្នកភូមិមួយចំនួនត្រូវចិនដែលជាប្រធានសន្តិសុខខ្មែរក្រហម បញ្ជាឱ្យឡើងកប៉ាល់ចេញពី ភូមិផ្លូវត្រី ឃុំថ្មគរ សំដៅទៅទីក្រុងភ្នំពេញ។ បន្ទាប់មក ខ្ញុំបានបន្តដំណើរទាំងយប់ទៅស្រុកមោង ខេត្តបាត់ដំបង តាមរថភ្លើង។ ប្រហែលជាម៉ោង៩ព្រឹក រថភ្លើងបានធ្វើដំណើរដល់ស្រុកមោង។ ពេលទៅដល់ស្រុកមោង ខ្ញុំសង្កេតឃើញមានរទេះគោនៅចាំទទួលប្រជាជន ហើយខ្មែរក្រហមបានចែកនំប៉័ងម្នាក់មួយដើម។ បន្ទាប់មក ក្រុមគ្រួសាររបស់ខ្ញុំត្រូវបញ្ជូនទៅកាន់សហករណ៍ភូមិបាណោក ជាប់ព្រៃនាម។ នៅទីនោះ អង្គការបានចែកអង្ករ ឬសណ្តែកបាយ ឬគ្រាប់ពោតឱ្យ។ ប៉ុន្តែរបបទាំងនោះពុំគ្រប់គ្រាន់ឡើយ។ មួយខែក្រោយមក ខ្មែរក្រហមបានចាត់តាំងឱ្យប្រជាជនហូបរួមនៅក្នុងសហករណ៍វិញ។ នៅរដូវច្រូតស្រូវ ប្រជាជនទទួលបានរបបហូបគ្រប់គ្រាន់។ ប៉ុន្តែនៅរដូវដកស្ទូង ប្រជាជនមិនបានទទួលរបបអាហារគ្រប់គ្រាន់ឡើយ។ ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ គឺជាឆ្នាំដែលអត់ឃ្លានបំផុត ដែលមានមនុស្សស្លាប់ស្ទើររាល់ថ្ងៃ។ ប្រជាជនមូលដ្ឋានជាអ្នកសែងសាកសពចេញទាំងថ្ងៃទាំងយប់។ ម្តាយរបស់ខ្ញុំ ក៏បានស្លាប់ដោយសារការអត់ឃ្លានដែរ។ មិនតែប៉ុណ្ណោះ ប្រសិនបើមាននរណាម្នាក់ហ៊ានលួចរបស់អង្គការ ហើយត្រូវអង្គការចាប់បាន អ្នកទាំងនោះនឹងត្រូវស្លាប់ជាមិនខាន។ ខ្ញុំមិនបានចាំឈ្មោះប្រធានសហករណ៍នោះ ទេ ដោយសារតែពេលវេលាកន្លងទៅយូរហើយ។

បើតាមខ្ញុំគិត មូលហេតុដែលខ្មែរក្រហមប្រព្រឹត្តិបែបនេះមកលើប្រជាជន ដោយសារតែខ្មែរក្រហមចង់សម្លាប់ប្រជាជន។ ទង្វើរបស់ខ្មែរក្រហមបានបង្ហាញយ៉ាងច្បាស់តាមរយៈ ការហូបមិនឆ្អែត ឬការសម្លាប់ដោយគ្មានការអប់រំណែនាំចំពោះកំហុសបន្តិចបន្តួច។ ការរស់នៅក្នុងរបបខ្មែរក្រហមអស់រយៈពេលជាងបីឆ្នាំដូចជាចុះនរកទាំងរស់។

នៅពេលដែលវៀតណាមចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងទាំងយប់ទាំងថ្ងៃជាមួយប្រជាជនដទៃទៀតស្ទើរគ្រប់ខេត្ត ត្រឡប់មកផ្ទះវិញ។ ជួនកាល ខ្មែរក្រហមបានជិះរទេះសេះមកបញ្ចុះបញ្ចូលប្រជាជន ឱ្យចូលរួមប្រយុទ្ធជាមួយវៀតណាម ប៉ុន្តែ ប្រជាជននាំគ្នាគេចខ្លួន។ អស់រយៈពេលជិតមួយខែ ទើបខ្ញុំធ្វើដំណើរដល់ស្រុកកំណើតរបស់ខ្ញុំវិញ។ ប្រជាជនណាមានសល់មាសប្រាក់ អាចឡើងជិះរថយន្តជាមួយកងទ័ពវៀតណាមបាន ដោយក្នុងមនុស្សម្នាក់ត្រូវបង់មាសមួយជី។ ខ្ញុំឃើញមានមនុស្សស្លាប់ជាហូរហែនៅតាមផ្លូវធ្វើដំណើរ ដោយសារអត់អាហារ និងអស់កម្លាំង។ មនុស្សម្នាក់ៗមានរូបរាងស្គមស្គាំងបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។

# រឿងរ៉ាវជនរងគ្រោះនៅខេត្តពោធិ៍សាត់ : សួន សៀង

ខ្ញុំបាទឈ្មោះ សួន សៀង ភេទប្រុស អាយុ៧០ឆ្នាំ មានបងប្អូនបង្កើត៥នាក់ (ស្រី១ ប្រុស៤) ហើយខ្ញុំជាកូនទី១។ នៅឆ្នាំ១៩៧៥ ប្អូនប្រុសរបស់ខ្ញុំឈ្មោះ ប៉ែន យន, ប៉ែន អ៊ុំ និង ប៉ែន អ៊ុន បានបែកពីខ្ញុំ។ ចំណែកខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅស្រុកបាកាន ខេត្តពោធិ៍សាត់។

ខ្ញុំជាអតីតទាហានជើងទឹកក្នុងជំនាន់ លន់ នល់ ដែលមាន មុំ សារុន (ផ្កាយ១) ជាប្រធាន។ នៅរដូវប្រ្ចូតឆ្នាំ១៩៧៨ យោធាខ្មែរក្រហមបានមកចាប់ខ្ញុំដោយចោទថា ខ្ញុំសម្តែងការមិនស្មោះត្រង់ចំពោះអង្គការ ហើយបានបញ្ជូនខ្ញុំទៅដាក់មន្ទីរសន្តិសុខតាលោ ក្នុងស្រុកបាកាន។ ខ្មែរក្រហមមិនបានធ្វើទារុណកម្មខ្ញុំទេ។ ប៉ុន្តែខ្ញុំត្រូវបង្ខំឱ្យធ្វើការធ្ងន់ធ្ងរ ហើយទទួលបានរបបអាហារតិចតួចបំផុត។ រហូតដល់ចុងឆ្នាំ១៩៧៨ ខ្ញុំលួចរត់ចេញពីមន្ទីរសន្តិសុខនៅពេលដែលកងទ័ពវៀតណាមចូលប្រទេសកម្ពុជា។

នៅឆ្នាំ១៩៧៦ មិត្តភ័ក្ត្ររបស់ខ្ញុំមួយចំនួនដូចជា កែវ (ស្រី) មឿន (ស្រី) ដែលធ្លាប់រស់នៅស្រុកមុខកំពូលជាមួយខ្ញុំប្រាប់ខ្ញុំថា ប្អូនៗប្រុសរបស់ខ្ញុំទាំង៣នាក់ ដែលជាអតីតនិស្សិត និងទាហានជំនាន់ លន់ នល់ ត្រូវខ្មែរក្រហមចាប់ដាក់គុកទួលស្លែង។ ខ្ញុំមានការសោកសង្រេងណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច ព្រោះមិនមែនមានតែប្អូនប្រុសរបស់ខ្ញុំទេដែលខ្មែរក្រហមសម្លាប់។ ខ្ញុំមិនបានដឹងថា គុកទួលស្លែងស្ថិតនៅទីក្រុងភ្នំពេញនោះទេ។ ខ្ញុំទើបតែដឹង នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញខ្ញុំឱ្យមកទស្សនកិច្ចនៅឆ្នាំ២០០៦ប៉ុណ្ណោះ។ ខ្ញុំធ្លាប់ស្វែងរកប្អូនប្រុសទាំងបី ដោយឱ្យគ្រូទាយមើលពីភ័ព្វវាសនារបស់ប្អូនប្រុសរបស់ខ្ញុំ។ ប៉ុន្តែគ្រូទាយប្រាប់ខ្ញុំថា អ្នកទាំងបីស្លាប់អស់ហើយ។

នៅឆ្នាំ១៩៧៧ ខ្ញុំបានឃើញខ្មែរក្រហមចាប់ចងស្លាបសេកប្រជាជន ដែលជម្លៀសពីខេត្តស្វាយរៀង ភូមិភាគបូព៌ា នៅពេលដែលខ្ញុំដឹកអុសមកឱ្យក្រុមផលិតស្ករត្នោត។ ខ្ញុំបានឮសំឡេងស្រែកអួយៗចេញពីក្នុងព្រៃ ខ្ញុំបានរត់ចេញមកវិញដោយសារខ្លាចខ្មែរក្រហមចាប់ខ្ញុំសម្លាប់ដែរ។ ភូមិទួលតាមោក ស្រុកបាកាន គឺជាកន្លែងដែលខ្មែរក្រហមចាប់អ្នកទោសមកពីខេត្តស្វាយរៀងយកទៅសម្លាប់។ បើតាមខ្ញុំដឹង ខ្មែរក្រហមចាប់ប្រជាជនទាំងនោះ ដោយចោទថាជាទាហានវៀតណាម ឬជាប់ពាក់ព័ន្ធនឹងវៀតណាម។

ខ្ញុំបាត់បង់ទ្រព្យសម្បត្តិដូចជាផ្ទះសំបែង គោក្របី ដីស្រែ នៅពេលខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជា។ ខ្ញុំមិនអាចគណនាជាតួលេខ អំពីអ្វីដែលខ្ញុំបាត់បង់បានទេ។ ជាងនេះទៅទៀត ខ្ញុំបានបាត់បង់ប្អូនប្រុសនៅក្នុងគុកទួលស្លែង ក្នុងរបបខ្មែរក្រហម។ ខ្ញុំមិនទាមទារជំងឺចិត្តបែបណានោះទេ ប៉ុន្តែខ្ញុំសុំឱ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់ជាទីបំផុត ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀតឡើយ។ សម្រាប់រូបខ្ញុំផ្ទាល់ ខ្ញុំចង់ឱ្យមានការសង់ជារូបសំណាក សម្រាប់រំឭកដល់របបខ្មែរក្រហម និងដើម្បីឱ្យប្រជាជនបានធូរស្បើយ។

# ស្ពានីយរថភ្លើងស៊ីសុផុន៖ រឿងរ៉ាវរបស់ ហាង្ស ប៉ូលីន

នៅឆ្នាំ១៩៧៦ ខ្ញុំ និងបងប្អូនសាច់ញាតិចំនួន១៤នាក់ ត្រូវកងទ័ពខ្មែរក្រហម ដែលមិនស្គាល់ឈ្មោះ ជម្លៀសចេញពីផ្ទះនៅស្រុកគៀនស្វាយ ទៅស្រុកស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ ដើម្បីធ្វើស្រែចម្ការ។ ខ្ញុំមិនបានដឹងពីមូលហេតុពិតប្រាកដនៃការជម្លៀស ឬនរណាជាអ្នកបញ្ជាឱ្យមានការជម្លៀសប្រជាជននោះទេ។ នៅពេលធ្វើដំណើរតាមផ្លូវ ខ្ញុំបានឃើញមនុស្សជាច្រើន ធ្វើដំណើរទៅកាន់បណ្តាខេត្តផ្សេងៗ។ កងទ័ពខ្មែរក្រហមមួយចំនួនបានឆែកឆេរឥវ៉ាន់របស់អ្នកដំណើរ។ នៅពេលនោះ ខ្ញុំបានឮប្តីរបស់ខ្ញុំឈ្មោះ នង ប៉ាក់ហ៊ាង និងឪពុកខ្ញុំឈ្មោះ ហាង ឡាយ បាននិយាយថាខ្មែរក្រហម កំពុងស្វែងរកមន្ត្រី រាជការសម័យមុន និងអ្នកចេះដឹង ដើម្បីប្រមូលដាក់មួយកន្លែង។

ក្រុមគ្រួសាររបស់ខ្ញុំ ត្រូវជម្លៀសទៅកាន់ខេត្តពោធិ៍សាត់។ បន្ទាប់មក ក្រុមគ្រួសាររបស់ខ្ញុំ ត្រូវជម្លៀសបន្តទៅកាន់ស្រុកសិរីសោភ័ណ (ស្វាយស៊ីសុផុន) ខេត្តបន្ទាយមានជ័យ។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យក្រុមគ្រួសាររបស់ខ្ញុំរស់នៅជុំគ្នានោះទេ។ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំចំនួន៧នាក់ ត្រូវបញ្ជូនទៅស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ចំណែកឯខ្ញុំ និងប្តីរបស់ខ្ញុំ ត្រូវបញ្ជូនទៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ទៅដល់ទីនោះ ខ្ញុំ និងប្តីរបស់ខ្ញុំ ព្រមទាំងប្រជាជនដទៃទៀតប្រហែលមួយរយនាក់ ដែលសុទ្ធតែជាបញ្ញវន្តដែលជម្លៀសមកពីទីក្រុងភ្នំពេញ ត្រូវខ្មែរក្រហមហៅឱ្យទៅរៀនសូត្រនយោបាយស្តីអំពី ទិសដៅការងារធ្វើស្រែចម្ការរបស់អង្គការនៅទីរួមស្រុកព្រះនេត្រព្រះ ចំនួនបីថ្ងៃ។ ថៅហ្វាយស្រុកឈ្មោះ ម៉ោង ជាអ្នកបង្រៀន។

ក្រោយពីរៀនចប់ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនត្រឡប់មកភូមិវិញ។ ចំណែកឯរូបខ្ញុំត្រូវខ្មែរក្រហមបញ្ជាឱ្យឡើងឡានដឹកទំនិញ ជាមួយប្រជាជនដទៃទៀតចំនួន១០នាក់។ បន្ទាប់មក ខ្មែរក្រហមបានចងស្លាបសេកអ្នកទាំងអស់គ្នា។ ខ្ញុំមានការភ័យខ្លាចជាខ្លាំង។ ក្រោយមក ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនទៅដាក់នៅក្នុងមន្ទីរឃុំឃាំងនៅស្វាយស៊ីសុផុន (ទីរួមស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ)។ ខ្ញុំត្រូវខ្មែរក្រហមដាក់ខ្នោះជើង មិនអាចដើរទៅណាមកណាបានទេ។ ខ្ញុំត្រូវខ្មែរក្រហមចាប់ឃុំឃាំងអស់រយៈពេលមួយខែ ដោយសារតែខ្ញុំជាបញ្ញវន្ត។ នៅក្នុងមន្ទីរឃុំឃាំង ខ្ញុំបានឃើញអ្នកដែលជាប់នៅក្នុងគុកជាមួយខ្ញុំត្រូវខ្មែរក្រហមដាក់ខ្នោះជើង និងបណ្តើរយកទៅវាយធ្វើបាបដល់ស្លាប់ ដោយសារបាននិយាយតវ៉ា និងប្រមាថមាក់ងាយអង្គការ។ បន្ទាប់មក ខ្ញុំត្រូវបញ្ជូនបន្តទៅលត់ដំនៅខេត្តបាត់ដំបង ជាមួយអ្នកទោសផ្សេងទៀតចំនួន២០០នាក់ដែលបានជាប់ឃុំជាមួយខ្ញុំនៅស្វាយស៊ីសុផុន។ ពេលទៅដល់ខេត្តបាត់ដំបង ខ្ញុំត្រូវបញ្ជាឱ្យធ្វើចម្ការ ដាំស្ពៃ ខាត់ណាដំឡូងមី នៅតាមដងស្ទឹងសង្កែ។ ខ្ញុំខិតខំធ្វើការងារទាំងអស់ដែលខ្មែរក្រហមបានចាត់តាំង ដោយសារតែខ្ញុំជាអ្នកទោសរហូតទទួលបានការសរសើរពីកម្មាភិបាលខ្មែរក្រហមដែលប្រចាំការនៅទីនោះ។

នៅខេត្តបាត់ដំបង ខ្ញុំបានជួបជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់ ដែលធ្លាប់ជាអតីតសិស្សឪពុកខ្ញុំ។ កម្មាភិបាលខ្មែរក្រហមរូបនោះបានស្គាល់ពីប្រវត្តិខ្ញុំ និងគ្រួសារខ្ញុំ ហើយបានជួយសង្គ្រោះខ្ញុំពីការធ្វើបាប។ រយៈពេលពីរខែក្រោយមក ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនមកជួបប្តីខ្ញុំ នៅភូមិគោកតាយា ឃុំជប់ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កម្មាភិបាលខ្មែរក្រហមរូបនោះបានផ្តាំខ្ញុំឱ្យខិតខំប្រឹងប្រែងធ្វើការងារ ក្រែងលោមានជីវិតរស់។ ខ្ញុំត្រូវធ្វើស្រែចម្ការ ទៅតាមការចាត់តាំងរបស់ប្រធានសហករណ៍។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមនាំយកមនុស្សចេញទៅ ប៉ុន្តែមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញឡើយ។

# រឿងរ៉ាវជនរងគ្រោះ មកពីខេត្តកំពង់ធំ ៖ នៀង យន់

## ការជម្លៀស

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមឈ្មោះ វង់, ឃុន និង លាប បានជម្លៀសខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំ ចេញពីភូមិទៅកាន់សហករណ៍ស្ពានឡក។ បើសិនជាខ្ញុំមិនព្រមទៅ ខ្មែរក្រហមនឹងបង្អត់អាហារ និងសម្លាប់ខ្ញុំ។ ប៉ុន្តែខ្ញុំមិនដឹងថាមូលហេតុអ្វីបានជាខ្មែរក្រហមបញ្ជាខ្ញុំឱ្យចេញពីភូមិនោះទេ។ បើតាមខ្ញុំគិត ប្រហែលជាខ្មែរក្រហមគិតថាខ្ញុំជាខ្មាំង ដោយសារតែខ្ញុំជាក្រុមថ្មីទីមួយ។ប្រជាជនដែលត្រូវជម្លៀសពីទីក្រុងភ្នំពេញគឺជាប្រជាជនក្នុងក្រុមទីពីរ។ ម្យ៉ាងទៀត ខ្ញុំត្រូវខ្មែរក្រហមចាត់ទុកថាជាជនបញ្ញើ ដែលនឹងត្រូវយកទៅសម្លាប់។ ចំណែកឯក្រុមទីពីរ នឹងត្រូវយកទៅសម្លាប់មុនគេ ដោយសារតែជនទាំងនោះជាអ្នកមាន មូលធន និងធ្លាប់ហូបឆ្ងាញ់។ រូបខ្ញុំ ក៏ត្រូវខ្មែរក្រហមចាត់ទុកថាជាក្រុមមូលធនដែរ ដោយសារតែខ្ញុំមានជីវភាពប្រសើរជាងប្រជាជនដទៃនៅក្នុងភូមិ។ ក្រុមគ្រួសាររបស់ខ្ញុំទាំងអស់ត្រូវខ្មែរក្រហមយកទៅសម្លាប់។ ខ្មែរក្រហមបានចាត់តាំងឱ្យខ្ញុំកាប់ព្រៃអស់រយៈពេលជាងមួយខែនៅសហករណ៍ស្ពានឡក។ បន្ទាប់មក វង់, ឃុន និង លាប បានបញ្ជូនខ្ញុំទៅភូមិពព្លូក ឃុំសំព្រោច ស្រុកស្ទោង។

## ការអត់អាហារ

នៅក្នុងឆ្នាំ១៩៧៥ដដែល ខ្ញុំត្រូវ វង់, ឃុន និង លាប បញ្ជូនទៅភូមិពព្លូក ស្រុកស្ទោង ដើម្បីធ្វើស្រែ។ ការធ្វើស្រែត្រូវងើបតាំងពីម៉ោង២ព្រឹក រហូតដល់ម៉ោង៦ល្ងាច។ ក្នុងអំឡុងពេលនោះ ខ្មែរក្រហមអនុញ្ញាតឱ្យសម្រាកតែកន្លះម៉ោងប៉ុណ្ណោះ គឺពេលសម្រាកអាហារពេលថ្ងៃត្រង់។ ខ្មែរក្រហមចែករបប បបរម្នាក់មួយវែកស្ទើរគ្មានគ្រាប់អង្ករលាយជាមួយត្រកួន។ នៅពេលនោះ ខ្ញុំមិនហ៊ានតវ៉ាជាមួយខ្មែរក្រហមទេ ដោយសារតែខ្ញុំខ្លាចខ្មែរក្រហមយកទៅសម្លាប់។ សម្រាប់អាហារពេលល្ងាច ខ្មែរក្រហមចែកអង្ករម្នាក់មួយស្លាបព្រា ប៉ុន្តែមិនបានពេញស្លាបព្រានោះទេ។ ជួនកាល ខ្មែរក្រហមចែកបបរឱ្យ តែរបបនោះមិនឆ្អែតទេ។ ដូច្នេះ ខ្ញុំបានលាយជាមួយព្រលិត ត្រកួន មើមល្ពុង ដើមចេក និងច្រវាទូកដែលដុះលើទឹក។ ជួនកាល ខ្ញុំទៅលួចយកកន្ធក់ និងអង្កាមមកទុក។ ពេលនោះ កន្ទក់ និងអង្កាមមានរសជាតិឆ្ងាញ់ណាស់ តែឥឡូវ ខ្ញុំហូបមិនចូលទេ។ ជួនកាល កុមារតូចៗលួចបូតស្រូវ។ នៅពេលដែលខ្មែរក្រហមចាប់បាន កុមារទាំងនោះត្រូវបានបង្អត់អាហាររហូតដល់ពេលល្ងាច ទើបដោះលែងទៅវិញ។ ពេលខ្លះ រឿង និង ក្អរ ដែលមានអាយុប្រហែល ២០ឆ្នាំ បានវាយកុមារតូចៗទាំងនោះ។ ចេក គឺជាអ្នកចែកអាហារ។ ចំណែកឯ យាយ យាន ជាអ្នកដាំបាយ។ យាយ យាន ជាមនុស្សកាច។ ប៉ុន្តែប្រសិនបើគាត់ចូលចិត្តនរណាម្នាក់ គាត់នឹងដួសបបរពីបាតឆ្នាំងមកឱ្យ។ ចំពោះប្រជាជនបញ្ញើវិញ យាយ យាន ដួសបបរឱ្យតែទឹកប៉ុណ្ណោះ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនផលិតស្រូវបានច្រើនណាស់ ប៉ុន្តែខ្មែរក្រហមមិនឱ្យហូបឆ្អែតសោះ។ ឪពុកម្តាយបង្កើត និងឪពុកម្តាយក្មេករបស់ខ្ញុំ ជីដូនខ្ញុំឈ្មោះ ដែក និងម្តាយមីងខ្ញុំឈ្មោះ យិន បានស្លាប់ដោយសារការអត់ឃ្លាន។

## ប្តីត្រូវខ្មែរក្រហមយកនៅសម្លាប់

នៅឆ្នាំ១៩៧៥ប្តីខ្ញុំឈ្មោះ យិប ហៀប អាយុ៣០ឆ្នាំ ត្រូវខ្មែរក្រហមចាប់ពីសហករណ៍ស្ពានឡក ទៅសម្លាប់នៅភូមិទពិច។ ខ្ញុំមិនហ៊ានទៅក្បែរភូមិនោះទេ។ ខ្ញុំខ្លាចខ្មែរក្រហមយកខ្ញុំទៅសម្លាប់។ បន្ទាប់ពីខ្មែរក្រហមសម្លាប់ប្តីខ្ញុំ ខ្មែរក្រហមបានយកក្រមា និងសារុងប្តីខ្ញុំមកឱ្យខ្ញុំ។ ប៉ុន្តែខ្ញុំមិនហ៊ានសួរនាំអ្វីនោះទេ ដោយសារតែខ្ញុំខ្លាច។ ពុយ អាយុប្រហែលជា៣០ឆ្នាំ ជាអ្នកប្រាប់ខ្ញុំថា គាត់បានឃើញខ្មែរក្រហមយកប្តីខ្ញុំទៅសម្លាប់នៅភូមិទពិច។

ចំណែកឯ បងប្រុសរបស់ខ្ញុំឈ្មោះ យិប អៀប, យិប អៀន, យិប ផេង ក៏ត្រូវ

ខ្មែរក្រហមឈ្មោះ សឿន ដែលមានប្រពន្ធឈ្មោះ ក្លែម ចាប់យកទៅសម្លាប់។ បងប្អូនរបស់ខ្ញុំត្រូវខ្មែរក្រហមចោទថាជាខ្មាំងអនុធន។ ខ្ញុំ និងកូន មិនអាចធ្វើអ្វីបានទាំងអស់ ក្រៅពីពួនយំ។

## ការសម្លាប់មនុស្ស

នៅឆ្នាំ១៩៧៥ ខ្ញុំបានឃើញ នុយ បណ្តើរប្រជាជនជាច្រើនដោយចងដៃទៅក្រោយ ដើម្បីយកទៅសម្លាប់នៅភូមិទពិច។ ខ្ញុំមិនហ៊ានសួរនាំអ្វីច្រើននោះទេ។ ប្រជាជនទាំងនោះត្រូវខ្មែរក្រហមចោទថា ជាខ្មាំង លួចអង្ករ លួចត្រី។ នៅក្នុងចំណោមប្រជាជនទាំងនោះ ខ្ញុំស្គាល់បុរសម្នាក់ឈ្មោះ ឆន ប្រហែលជា៥០ឆ្នាំ មកពីឃុំត្រាចជ្រុំ។ ទន្ទឹមនឹងនេះដែរ ខ្ញុំក៏ធ្លាប់ឃើញខ្មែរក្រហមយកអ្នកដែលធ្វើការនៅក្នុងកងជាមួយខ្ញុំទៅសម្លាប់ចោល ដោយសារអ្នកទាំងនោះបានធ្វើបែកចាន បាក់នង្គ័ល បាក់ផាល។ ខ្ញុំមិនបានដឹងថា ខ្មែរក្រហមយកមនុស្សទៅសម្លាប់នៅកន្លែងណានោះទេដោយសារតែខ្មែរក្រហមនាំមនុស្សចេញទៅនៅពេលយប់។ ប្រជាជនដែលខ្មែរក្រហមយកទៅសម្លាប់នោះត្រូវហៅឱ្យទៅដាំដំឡូង។

## ការធ្វើទុក្ខបុកម្នេញ

នៅឆ្នាំ១៩៧៧ ប្អូនប្រុសរបស់ខ្ញុំឈ្មោះ សេង នុន អាយុ២២ឆ្នាំ ត្រូវប្រធានឈ្លបឈ្មោះ ហាប យកទៅដាក់គុកនៅទួលភ្លូង ស្ថិតនៅខាងជើងផ្សារស្ទោង។ ខ្ញុំមិនបានដឹងថាប្អូនប្រុសរបស់ខ្ញុំបានប្រព្រឹត្តខុសអ្វីទេ។ ប៉ុន្តែ មួយខែក្រោយមកប្អូនប្រុសរបស់ខ្ញុំត្រូវដោះលែងវិញ។ ខ្មែរក្រហមបានដាក់ខ្នោះជើងប្អូនខ្ញុំ និងបានបង្អត់អាហារបីបួនថ្ងៃ ដោយមិនបានវាយដំប្អូនខ្ញុំនោះទេ។

## ការរំលោភលើរូបរាងកាយស្ត្រី ដែលជាប្រជាជន១៧មេសា

នៅឆ្នាំ១៩៧៨ កងឈ្លបឈ្មោះ ចន បានលួចខ្សឹបប្រាប់ខ្ញុំថា កម្មាភិបាលខ្មែរក្រហមបានចាប់រំលោភស្ត្រីម្នាក់ រួចសម្លាប់ចោលនៅដូនសុក ឬត្រពាំងដូនសុក។ ចន មិនបានប្រាប់ខ្ញុំថា កម្មាភិបាលរូបនោះឈ្មោះអ្វីទេ។ ស្ត្រីរងគ្រោះនោះឈ្មោះគ្រុយ។ ប្តីរបស់ គ្រុយ ត្រូវបានចោទថាជាមន្ត្រីស័ក្តិបី។

# ប្រវត្តិភូមិ អូរដំបង ខេត្តចាត់ដំបង : ប៊ី ប៉េង

នៅឆ្នាំ១៩៧៥ កងកម្លាំងខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងស្រុង។ ដោយឡែកនៅភូមិអូរដំបង ប្រជាជនត្រូវជម្លៀសចេញពីដើមភូមិទៅនៅចុងភូមិទួលម៉ុង អូររុន និង បឹងខ្វាស់។ ការបែងចែកដំបូងត្រូវធ្វើឡើងដោយមានខ្សែទី១ ប្រជាជនភាគច្រើនមកពីផ្សារក្នុងភូមិទួលម៉ុង។ ខ្សែទី២ ខ្សែទី៣ ខ្សែទី៤ និងខ្សែទី៥ ជាប្រជាជនរស់នៅភូមិអូរដំបង នៅម្តុំបឹងខ្វាស់។ ប្រជាជនត្រូវធ្វើជម្រករស់នៅដោយខ្លួនឯងក្នុងឆ្នាំ១៩៧៥។ ក្នុងការជម្លៀសនេះ គឺអង្គការបានឱ្យធ្វើផ្ទះក្នុងមួយគ្រួសារ ១ខ្នង ទំហំ ៣ម៉ែត្រ គុណ៤ម៉ែត្រ។

## ការធ្វើការងារ

ការងារធ្វើជាក្រុម និងកង។ កងចាស់ៗ មានដូចជា អ្នកមានប្តីប្រពន្ធ មេម៉ាយ ឬពោះម៉ាយ។ កងយុវជនមានមេកងឈ្មោះ មិត្តសុខ មិត្តភាព និង មិត្តពត។ កងធំមាន មិត្តវ៉ើន និង មិត្តភាន បន្ទាប់មកបែងចែកជាកង ក្រុម និងពួក។ ក្នុងចំណោមនោះចែកចេញជាកងធ្វើចម្ការដែលមាន មិត្តពត ជាអ្នកគ្រប់គ្រង។ ចំណែកកងចល័តសម្រាប់លើកទំនប់ជីកប្រឡាយ ធ្វើស្រែ មាន មិត្តសុខ និង មិត្តភាព ជាអ្នកគ្រប់គ្រង។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺប្រជាជនទាំងអស់សុទ្ធតែមានការងារធ្វើទាំងអស់គ្នា ទោះបីជាអ្នកនោះមានស្ថានភាពសុខភាពយ៉ាងណាក៏ដោយ ក៏នៅតែមានការងារធ្វើជានិច្ច។ បើអ្នកណាខ្ជិល អង្គការចាត់ទុកថាអ្នកនោះជាអ្នកមានជំងឺសតិអារម្មណ៍ ហើយលើកឡើងថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ឬអាចហៅម៉្យាងទៀតថា "គ្មានញាក់គ្មានញ័រ គ្មានគ្រាក់ទ័រ គ្មានឡាន គ្មានបាយបាន គ្មានខ្នងពូថៅ"។

ក្នុងរបបខ្មែរក្រហម ប្រជាជនទូទៅធ្វើការងារគ្មានពេលទំនេរ មិនមានថ្ងៃបុណ្យ ថ្ងៃអាទិត្យ និងធ្វើការហួសម៉ោងកំណត់។ ពេលយប់ប្រជុំជីវភាព ពេលព្រឹកងើបពីម៉ោង៤ទៅធ្វើការ ដែលទាំងនេះកាន់តែបង្កឱ្យបញ្ហាសុខភាពប្រជាជនធ្លាក់ដុនដាប។

## ការហូបចុក

ហូបរួមតាមសហករណ៍ (ភូមិ) ក្រោយមកទើបហូបតាមកង។ ចំណែក យុវជនហូបតាមកងយុវជន ឯយុវនារី គឺនៅតាមកងនារី។ ម៉្យាងទៀតការរស់នៅគឺផ្សេងគ្នា យុវជននៅខាង តាឌុល ឯនារីនៅលីវនៅខាង តាស៊ុន។

ក្រោយរដូវច្រូតកាត់រួចប្រហែល៣-៤ខែក្រោយមក ប្រជាជនបានហូបបាយចែកមួយចានចង្កឹះម្នាក់ ដល់ខែចុះធ្វើស្រែគឺហូបបបរ ចែកម្នាក់មួយវែកត្រឡោក(បបររាវ)។ ដល់ចុងខែតុលា គឺបបររាវតែម្តង មួយកំប៉ុងមួយខ្ទះ ដោយលាយជាមួយគ្រាប់ពោត។ ពេលខ្លះចែកនំកន្ទក់ (កន្ទក់ជ្រូក) នំចេកបុក ឬដំឡូងដាំក្នុងចម្ការ ចម្ការកោះ ដែលមានអូរព័ទ្ធជុំវិញ។ នៅទីនោះជាទីតាំងយោធា ដែលមានតែយោធា និងប្រពន្ធកូនតែប៉ុណ្ណោះ។ ប្រជាជនទូទៅមិនអាចរស់នៅទីនោះបានទេ។

ក្នុងរបបខ្មែរក្រហម អ្នកដែលត្រូវជាប់ចោទថាក្បត់នឹងអង្គការត្រូវយោធានាំយកទៅដាក់លើកោះនោះ ហើយយកទៅដាក់ក្នុងអាគារធំនៅកណ្តាល ជាន់លើ ដោយធ្វើទារុណកម្ម រួចក៏យកទៅទម្លាក់ក្នុងអណ្តូងក្បែរអាគារនោះ។ ជួនកាលអ្នកទាំងនោះត្រូវយកទៅកន្លែងតារ៉ែ(នៅជំនីក)ឬទៅវត្តសំរោង។បើតាមសម្តីចាស់ៗបានដឹងថាសាកសពដែលទម្លាក់ក្នុងអណ្តូងមានចំនួនប្រហែល៣០នាក់ មានទាំងក្មេងទាំងចាស់ ដែលក្រោយមក ត្រូវរកឃើញនៅពេលស្តារអណ្តូងប្រើប្រាស់។

ចំពោះអ្នកស្លាប់នៅពេទ្យ សាកសពទាំងអស់ ត្រូវគេយកកប់តាមរបងមន្ទីរពេទ្យដែលមិនដឹងចំនួនពិតប្រាកដ។

នៅឆ្នាំ១៩៧៨ ភូមិអូរដំបង ត្រូវគ្រប់គ្រងដោយខ្មែរក្រហមមកពីភូមិភាគនិរតី។ ចំណែកខ្មែរក្រហមនៅក្នុងភូមិភាគពាយ័ព្យ ត្រូវបានខ្មែរក្រហមមកពីភូមិភាគនិរតីគ្រប់គ្រង ឬយកទៅសម្លាប់តែម្តង។

## ប្រភេទការងារ និង ថ្នាក់ដឹកនាំ

ក្នុងរបបខ្មែរក្រហម មនុស្សចាស់ដែលមានគ្រួសារ យុវជន យុវនារី និងកុមារដែលមានអាយុលើសពី៥ឆ្នាំ ត្រូវរស់នៅដោយឡែក។

អ្នកដែលមានគ្រួសារត្រូវបំបែកចេញពីគ្នា ដោយចែកចេញជា បុរសធ្វើការនៅក្នុងកងភ្ជួរ (ភ្ជួរស្រែ) ធ្វើជារោងនៅតាមស្រែ រកអុស បោចវល្លិ៍ ឬកងដឹកជញ្ជូន។ រីឯស្ត្រីជាអ្នកដកស្ទូង ច្រូតកាត់ ឬជាអ្នកធ្វើចម្ការ។

យុវជន និង យុវនារីនៅលីវត្រូវបំបែកឱ្យនៅផ្សេងគ្នា ដោយយុវជន នៅក្នុងភូមិដែលមាន តា ឌុល មិត្តសុខ មិត្តភាព និងមិត្តពត ជាអ្នកក្តាប់។ មិត្តសុខ និងមិត្តភាព ជាអ្នកដឹកនាំយុវជនធ្វើការ ដូចជាលើកទំនប់ ជីកប្រឡាយ លើកភ្លឺស្រែ ជួយរែកកណ្តាប់និងដកស្ទូង។ ចំណែក មិត្តពត ជាអ្នកក្តាប់យុវជនធ្វើចម្ការ។ យុវនារីស្នាក់នៅភូមិមួយផ្សេង ដែលមាន តាស៊ុន តារិន និងប្រពន្ធឈ្មោះ លី ជាអ្នកគ្រប់គ្រង។ មិត្តនារីយានមិត្តសឿន មិត្តរដ្ឋ ជាអ្នកដឹកនាំនារីលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ ដកស្ទូង ច្រូតកាត់ និងធ្វើចម្ការ។

កុមារជំទង់ត្រូវជួយបោចស្មៅក្នុងស្រែ ជញ្ជូនដើមទន្រ្ទានខែត្រមកដាក់ក្នុងរោងធ្វើជីដែលមានចាស់ៗជាអ្នកចិញ្ច្រាំទុកសម្រាប់យកទៅដាក់ក្នុងស្រែ។

## ការរៀបការនៅក្នុងរបបខ្មែរក្រហម

បុរស និងនារីច្រើនគូឈរនៅទល់មុខគ្នានៅក្នុងសហករណ៍ ឬភូមិដែលមានមេភូមិ ឬគណៈសហករណ៍ជាអ្នកប្រកាស។ បន្ទាប់មកបុរសនារីត្រូវចាប់ដៃគ្នា (បុរសដើរទៅចាប់ដៃនារី) ហើយជួនកាលអាចខុសគូគ្នាក៏មានដែរ។ ពេលចាប់ដៃរួច គូស្វាមីភរិយាត្រូវធ្វើការប្តេជ្ញាចិត្តចំពោះមុខអង្គការ ម្តងមួយគូៗរហូតដល់ចប់។

ពេលចូលរួមដំណេក មានកងឈ្លបជាអ្នកចាំលបស្តាប់ ប្រសិនបើមានការមិនត្រូវគ្នា (ប្រកែក) ព្រឹកឡើងអង្គការបាននាំអ្នកទាំងពីរទៅរៀនសូត្រ ឬសម្លាប់ចោលតែម្តង។

ការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបប៣ឆ្នាំ៨ខែ២០ថ្ងៃ ជីវិតរស់នៅសែនលំបាកវេទនាបំផុតទាំងការធ្វើការងារគ្មានពេលសម្រាក ការហូបចុកពុំគ្រប់គ្រាន់ កន្លែងស្នាក់ខ្វះអនាម័យ (មិនសមរម្យ) សម្ភារៈសម្រាប់ប្រើប្រាស់គ្មាន គឺមានតែមួយចង់តូចតែប៉ុណ្ណោះ។

ពុំមានការដោះដូរទំនិញឡើយ (គ្មានទីផ្សារ) ពុំមានសាលារៀន មានតែសាលាធ្វើ។

ភាពខ្មៅងងឹត ខ្លោចផ្សា បែកបាក់ ទារុណកម្ម បង្អត់អាហារ ធ្វើការគ្មានពេលម៉ោងធ្វើឱ្យប្រជាជនស្លាប់បាក់កម្លាំង ឈឺ សំខាន់បំផុត គឺផ្នែកសេដ្ឋកិច្ចធ្លាក់ចុះខ្ទេចខ្ទីគ្មានសល់អ្វីឡើយ។

ចុងបញ្ចប់នៃការរៀបរាប់នេះ បានបង្ហាញភាពជាក់ស្តែង ដែលខ្លួនខ្ញុំបាទផ្ទាល់បានឆ្លងកាត់ និងខិតខំតស៊ូដើម្បីឱ្យការរស់នៅនាសម័យនោះបានរួចខ្លួនមួយរយៈ ទម្រាំតែប្រទេសត្រូវរំដោះឱ្យផុតពីរបបខ្មៅងងឹតចាក់ស្រេះ កាប់សម្លាប់ ធ្វើបាបតែគ្នាឯង ដោយការគុំគួន បែងចែកវណ្ណៈ គួរឱ្យស្អប់ខ្ពើមបំផុត។

# រឿងរ៉ាវពីខេត្តស្វាយរៀង : វ៉ាន់ សន

មុនឆ្នាំ ១៩៧៥ ពេលដែលខ្មែរក្រហមកាន់កាប់បានទីក្រុងភ្នំពេញ ខ្ញុំគឺជាអតីតទាហាន លន់ នល់។ ខ្ញុំត្រូវវាយជាមួយទ័ពខ្មែរក្រហមនៅទីក្រុងភ្នំពេញ។ ពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ ខ្ញុំត្រូវខ្មែរក្រហមចាប់យកទៅដាក់នៅមន្ទីរសន្តិសុខត្រពាំងត្រាច នៅភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ អ្នកដែលចាប់យកខ្ញុំទៅដាក់នៅមន្ទីរសន្តិសុខ គឺជាកងសន្តិសុខខ្មែរក្រហមនៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលប្រដាប់ដោយកាំភ្លើងគ្រប់ដៃ។ ខ្ញុំមិនស្គាល់ឈ្មោះសន្តិសុខស្រុកនោះទេ។ អ្នកដែលត្រូវខ្មែរក្រហមចាប់យកទៅជាមួយខ្ញុំ សុទ្ធតែជាអតីតទាហានសម័យ លន់ នល់ ដែលនៅក្នុងក្រុមជាមួយខ្ញុំដែរ មានគ្នាប្រហែលជា៣០០នាក់។ នៅគុកត្រពាំងត្រាច កងឈ្លប៣ទៅ៤នាក់មកពីឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ជាអ្នកយាមគុក។

ឈ្លបយាមគុកកាន់កាំភ្លើងគ្រប់ដៃ។ នៅទីនោះ ខ្មែរក្រហមបញ្ជាឱ្យជីកប្រឡាយនៅឃុំស្វាយ តាយាន ស្រុកកំពង់រោទិ៍ ឈ្មោះ "ប្រឡាយស្រុក"។ ក្នុងមួយថ្ងៃ ខ្មែរក្រហមកំណត់ជីកឱ្យបាន៤ម៉ែត្រគូប។ បើមិនរួចតាមកាលកំណត់ ខ្មែរក្រហមមិនឱ្យរបបអាហារឡើយ។ ក្នុងមួយថ្ងៃ ខ្មែរក្រហមចែកអង្ករម្នាក់៣ស្លាបព្រា និងអំបិល៣គ្រាប់។ រយៈពេល៣ខែក្រោយមក អ្នកទោសដែលនៅក្នុងគុកត្រពាំងត្រាចទាំងអស់ ត្រូវខ្មែរក្រហមជម្លៀសទៅកាន់មន្ទីរសន្តិសុខវត្តរំដួលក្នុងឃុំរំដួលស្រុកស្វាយទាបខេត្តស្វាយរៀង។កងសន្តិសុខមកពីស្រុកកំពង់រោទិ៍ប្រហែលជាបួនប្រាំនាក់ជាអ្នកយាមនៅទីនោះ។ ខ្មែរក្រហមបានបញ្ជាឱ្យអ្នកទោសធ្វើផ្ទះនៅសាលាស្រុកកំពង់រោទិ៍។ ខ្ញុំ និងអ្នកទោសដទៃទៀតពុំមានសិទ្ធិទៅលេងបងប្អូនសាច់ញាតិដូចប្រជាជនទូទៅទេ។ បើមាននរណាម្នាក់ចង់បត់ជើងតូចបត់ជើងធំ ត្រូវស្រែកសុំអ្នកយាម បើមិនដូច្នេះទេអ្នកទោសនោះនឹងត្រូវកងសន្តិសុខវាយនឹងដំបងរហូតដល់សន្លប់។

បន្ទាប់ពីជាប់ឃុំឃាំងនៅវត្តរំដួលបានប្រហែល ៣ ឬ៤ខែ ខ្ញុំ និងអ្នកទោសដទៃទៀតត្រូវខ្មែរក្រហមជម្លៀសទៅកាន់វត្តពោធិ៍ថ្មី។ កាលពីជាប់ឃុំឃាំងនៅវត្តរំដួល មិត្តភក្តិខ្ញុំឈ្មោះ វណ្ណា (អតីត ទាហាន លន់ នល់) ត្រូវកងសន្តិសុខវត្តរំដួលបញ្ជូនយកទៅសម្លាប់នៅគុកឫស្សីសាញ់ (គុកធំរបស់ស្រុកកំពង់រោទិ៍) ដោយសារតែគាត់បានលួចរត់ទៅលេងផ្ទះ។ ពេលមកដល់វត្តពោធិ៍ថ្មី ខ្មែរក្រហមបានជ្រើសរើសអ្នកទោសដែលមានកម្លាំងខ្លាំងឱ្យចេញទៅកាន់តំបន់ផ្សេង ហើយរក្សាទុកអ្នកទោសដែលខ្សោយឱ្យស្ថិតនៅក្នុងមន្ទីរសន្តិសុខនេះដដែល។ វត្តពោធិ៍ថ្មី ស្ថិតនៅឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ កងសន្តិសុខប្រហែល៥នាក់ ជាអ្នកក្តាប់អ្នកទោសនៅក្នុងក្រុមខ្ញុំមានគ្នាប្រហែល១០០នាក់ និងអ្នកមកពីក្រុមដទៃទៀតសរុបប្រហែល៥០០នាក់។ នៅពោធិ៍ថ្មីបានប្រហែលកន្លះខែ ខ្មែរក្រហមក៏បានបញ្ជូនខ្ញុំទៅមន្ទីរសន្តិសុខព្រះពន្លា ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ នៅវត្តព្រះពន្លា មានប្រធានសន្តិសុខ ឈ្មោះ ធឿន ជាអ្នកសួរចម្លើយ ហើយមានឈ្មោះ រឿន ជាអ្នកបណ្តើរប្រជាជនចេញទៅធ្វើការ។ អ្នកដែលមានសក្តិធំ ខ្មែរក្រហមជ្រើសរើសដាក់នៅមួយកន្លែង ដើម្បីត្រៀមបញ្ជូនទៅដាក់ឃុំឃាំងនៅគុក ឫស្សីសាញ់ ដែលជាគុកធំនៅស្រុកកំពង់រោទិ៍។ ខ្ញុំជាពលទោត្រូវខ្មែរក្រហមចម្រាញ់ដាក់នៅម្ដុំ។ ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឱ្យមកធ្វើការនៅសហករណ៍ព្រៃចារ ឃុំខ្សែត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ អ្នកទោសដែលជាអតីតទាហាន លន់ នល់ ដូចរូបខ្ញុំ ហើយដែលមានជីវិតនៅរស់សព្វថ្ងៃមានឈ្មោះ សេក រ៉ុង (សព្វថ្ងៃរស់នៅភ្នំពេញ) ចាន់ត្រឿង (សព្វថ្ងៃរស់នៅភូមិសំយ៉ោង ឃុំសំយ៉ោង ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង) ប្រ៊ុញ សេង (សព្វថ្ងៃរស់នៅភូមិរោទិ៍ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង)។

# បូជនីយដ្ឋាន រណ្ដៅសាកសព និងគុក នៅស្រុកបាទី ខេត្តតាកែវ

## វត្តសូភី ហៅ កកោះ

រហូតមកដល់ឆ្នាំ២០០០ នៅពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅធ្វើការស្រាវជ្រាវនៅវត្តសូភី ហៅ កកោះ វត្តនេះនៅមានបន្សល់ទុកស្លាកស្នាមយ៉ាងច្បាស់ៗនូវស្នាមប៉ះស៊ីម៉ង់ត៍ថ្មីៗគ្រប់រន្ធ។ ខ្មោះជាច្រើនត្រូវដាក់ដំកល់ក្នុងបូជនីយដ្ឋានជាមួយអដ្ឋិធាតុមួយចំនួន ដែលត្រូវគាស់ដោយប្រជាជននៅជុំវិញបរិវេណវត្តនេះកាលពីឆ្នាំ១៩៨០។ សង្ឃដីការបស់ព្រះតេជគុណ កែវ កុសល ថា អដ្ឋិធាតុដែលបានគាស់រួចមកនេះ ស្មើនឹងមួយភាគប្រាំនៃឆ្អឹងទាំងអស់។ កន្លែងតម្កល់អដ្ឋិធាតុស្ថិតនៅខាងកើតឆៀងខាងត្បូងព្រះវិហារវត្តកកោះ។ នៅថ្ងៃ២០ ឧសភា ស្ទើរតែរាល់ឆ្នាំមានព្រះសង្ឃ១០០អង្គ ព្រមទាំងប្រជាជនរាប់ពាន់នាក់ក្នុងស្រុក បានមកធ្វើបុណ្យឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធអ្នកដែលបានស្លាប់ទាំងនោះ ឱ្យទៅកាន់សុគតិភព។ ព្រះតេជគុណ កែវ កុសល បានសាងសង់កុដិមួយនៅក្បែរអតីតរណ្ដៅសាកសពទាំងនោះ ហើយព្រះតេជគុណបានជីកដីនៅក្បែរនោះមកដំកល់ជើងតាង។ នៅពេលដែលជីកបានជម្រៅប្រហែលកន្លះម៉ែត្រ និងទំហំប្រហែលកន្លះម៉ែត្រ ក៏បានប្រទះឃើញខោអាវដែលមិនទាន់ពុកផុយ ព្រមទាំងឆ្អឹងមួយចំនួនទៀត។ ឆ្អឹងនោះមានចំនួនជិតមួយបង្គី ហើយភាគច្រើនជាឆ្អឹងស្មងជើង និងឆ្អឹងដើមដៃជាដើម។ ព្រះតេជគុណបាននាំយកឆ្អឹងទាំងនោះ ទៅដាក់ដំកល់ជាមួយអដ្ឋិធាតុជាច្រើនទៀតដែលមាននៅក្នុងបូជនីយដ្ឋាន។ យប់ថ្ងៃដដែលនោះ ក៏មានព្រះសង្ឃអង្គផ្សេង ស្រមៃឃើញស្ទើរនឹងភ្នែកស្រស់ទាំងកណ្ដាលយប់នូវហ្វូងមនុស្សប្រុសស្រី ចាស់ក្មេង នាំគ្នាដើរឡើងសំដៅទៅកាន់ព្រះវិហារវត្តកកោះ។ ព្រះសង្ឃ កែវ កុសល មានសង្ឃដីកាថាជាព្រលឹង ដែលមិនទាន់ស្ងប់របស់ជនរងគ្រោះ។

## រណ្ដៅសាកសពនៅស្រុកបាទី

១) វត្តសូភី (វត្តកកោះ) ៖ រណ្ដៅចំនួនប្រហែល ១០០០ ជនរងគ្រោះ ២០,០០០នាក់
២) វត្តទ្រព្យគរ ៖ រណ្ដៅចំនួនប្រហែល ៧៦ ជនរងគ្រោះ ៣០,០០០-៤០,០០០នាក់
៣) ត្រពាំងស្នួង និងត្រពាំងអណ្ដូង ៖ រណ្ដៅចំនួនប្រហែល ៧៦ ជនរងគ្រោះ ១០,០០០នាក់
៤) ត្រពាំងច្រនាង ៖ រណ្ដៅចំនួនមិនដឹងប្រាកដ ជនរងគ្រោះ ១០០នាក់

## មន្ទីរសន្តិសុខវត្តកកោះ

វត្តសូភី ហៅ កកោះ មានទីតាំងស្ថិតនៅក្នុងភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី។ ខ្មែរក្រហមបានយកវត្តកកោះធ្វើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស តាំងពីឆ្នាំ១៩៧៣មក។ អ្នកទោសដំបូងបង្អស់ ដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះ គឺជាប្រជាជនមូលដ្ឋាន។ សូរ ញ៉ អាយុ៦៩ឆ្នាំ បច្ចុប្បន្នមានទីលំនៅ នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី គឺជាអតីតអ្នកទោសដែលជាប់ក្នុងមន្ទីរសន្តិសុខវត្តកកោះ កាលពីចុងឆ្នាំ១៩៧៣។ ញ៉ បាននិយាយថា គាត់ត្រូវកងសន្តិសុខចាប់ខ្លួនពីបទជេរប្រទេចខ្មែរក្រហម។ នៅពេលដែលគាត់ជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ គាត់បានឃើញអ្នកទោសជាប់ខ្នោះពីរជួរ ដែលក្នុងមួយជួរៗមានអ្នកទោសពី២០ទៅ៣០នាក់។

ក្រោយពីបរិវេណវត្តកកោះត្រូវខ្មែរក្រហមជ្រើសរើសធ្វើជាមន្ទីរសន្តិសុខ ប្រជាជនដែលរស់នៅក្បែរៗនោះត្រូវជម្លៀសចេញទៅកាន់តំបន់ឆ្ងាយៗគ្មានសល់ម្នាក់ឡើយ ហើយបរិវេណវត្តទាំងមូល ត្រូវខ្មែរក្រហមហាមឃាត់មិនឱ្យប្រជាជនចេញចូលដោយសេរីទេ។ សូរ ញ៉ បាននិយាយថា អ្នកទោសខ្លះ ស្លាប់ដោយសារការបង្អត់អាហារ ការធ្វើទារុណកម្ម និងខ្លះទៀតត្រូវកងសន្តិសុខសម្លាប់យ៉ាងព្រៃផ្សៃ។

ពុត ជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខវត្តកកោះដំបូងគេបង្អស់។ ពុត បានដាក់បញ្ជាឱ្យកងសន្តិសុខរបស់ខ្លួនប្រាប់អ្នកទោសដែលត្រូវនាំយកទៅសម្លាប់ថា ត្រូវផ្លាស់ប្ដូរទៅកាន់ "តំបន់" ដើម្បីទទួលភារកិច្ចថ្មី។ សូរ ញ៉ រំឭកថា អ្នកទោសគ្រប់គ្នាខ្លាចណាស់ចំពោះពាក្យថា "ត្រូវផ្លាស់ទៅកាន់តំបន់" ព្រោះដឹងថា មុខជាស្លាប់មិនខាន។

នៅដើមឆ្នាំ១៩៧៤ សូរ ញ៉ ត្រូវដោះលែងឱ្យមកកាន់លំនៅដ្ឋានវិញ ប៉ុន្តែគាត់ត្រូវសមមិត្ត ពុត ប្រាប់ឱ្យសន្យាថានឹងមិននិយាយប្រាប់គេឯងឱ្យដឹងពីការសម្លាប់មនុស្ស ការហូបមិនឆ្អែត និងការធ្វើទារុណកម្មអ្នកទោស នៅក្នុងមន្ទីរសន្តិសុខវត្តកកោះនេះឡើយ។

ក្រោយថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងសន្តិសុខបានចាប់អ្នកទោសបញ្ជូនមកឃុំឃាំងជាបន្តបន្ទាប់។ ប៊ុន ហ៊ីង ដែលមានស្រុកកំណើតនៅឃុំចំបក់ ស្រុកបាទី ហើយបច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិក បានរាយការណ៍ឱ្យដឹងពីទីកន្លែងឃុំឃាំងសួរចម្លើយ និងសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តសូភី ហៅវត្តកកោះ ថា "នៅឆ្នាំ១៩៧៥ កងសន្តិសុខបាន

សម្លាប់មនុស្សយ៉ាងច្រើន នៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តកកោះ។ កាលនោះប្រជាជនដែលអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយធ្វើដំណើរឆ្លងកាត់តាមផ្លូវជាតិលេខ២ និងលេខ៣ ត្រូវកងសន្តិសុខកៀរបញ្ចូលមកកាន់វត្តកកោះមួយចំនួន និងទៅកាន់វត្តទ្រព្យគរមួយចំនួន។ ប្រជាជនជម្លៀសទាំងនោះត្រូវសម្លាប់ទម្លាក់ក្នុងស្រះទឹកជុំវិញព្រះវិហារវត្តកកោះ ដែលមានទំហំប្រមាណជា៥០ម៉ែត្រការ៉េ និងជម្រៅប្រហែល ៤ម៉ែត្រ នៅប៉ែកខាងជើង ខាងកើត និងខាងត្បូងបរិវេណវត្ត។ សាកសពដែលកងសន្តិសុខសម្លាប់នៅជុំវិញបរិវេណវត្តកកោះមានទាំងក្មេងចាស់ ប្រុសស្រីរាប់ម៉ឺននាក់។ សាកសពគរលើគ្នាកម្ពស់ប្រមាណ២ម៉ែត្រ។ ការសម្លាប់ប្រជាជនជម្លៀសបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨ រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥"។ ប៊ុន ហ៊ីង បានឱ្យដឹងថា ឈ្មោះ អ៊ុយ មេបញ្ជាការរងភូមិភាគនិរតី ជាអ្នកសម្លាប់មនុស្សច្រើនជាងគេ។ ចាប់ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់ និងការចាប់មនុស្សមកដាក់ឃុំឃាំងនៅតែបន្ត។ អ្នកទោសដែលជាប្រជាជនមូលដ្ឋាន និងប្រជាជនជម្លៀសកាន់តែច្រើនឡើងបានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខវត្តកកោះ។ ទឹម គុណ និង មុយ ចក់ ជាប្រជាជនមូលដ្ឋានដែលមានកំហុស ហើយត្រូវកងសន្តិសុខចាប់ខ្លួន មកដាក់នៅមន្ទីរសន្តិសុខវត្តកកោះតាំងពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨ បានប្រាប់ថា អ្នកទោសស្ទើរតែទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅប៉ែកខាងកើត ខាងលិច ខាងជើង ខាងត្បូងព្រះវិហារ ខាងក្នុងបរិវេណសាលាបឋមសិក្សាសូភី និងនៅមាត់ត្រពាំងខាងជើងសាលារៀន ដោយប្រើដំបង ត្បូងចប និងដែកគ្លៀរទេះជាឧបករណ៍សម្លាប់មនុស្ស។ ការសម្លាប់ច្រើនប្រព្រឹត្តទៅនៅម៉ោង៣រសៀល ដោយមានចាក់ភ្លេងខ្លាំងៗ ដើម្បីបន្លប់សំឡេងស្រែករបស់អ្នកទោស។ នៅឆ្នាំ១៩៧៨ មុនពេលសមមិត្ត ពុត ត្រូវអង្គការផ្លាស់ចេញ ព្រោះរឿងខុសសីលធម៌ជាមួយនារីម្នាក់ ហើយដាក់សមមិត្ត កន ដែលជាប្អូនរបស់សមមិត្ត ជីម ជាគណៈស្រុកបាទីជំនួសវិញនោះ អ្នកទោសជាច្រើនដែលជាប់នៅក្នុងមន្ទីរសន្តិសុខវត្តកកោះ ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោល។ ទឹម គុណ បាននិយាយថា ក្នុងពេលដែលសមមិត្ត ពុត នៅគ្រប់គ្រងមន្ទីរសន្តិសុខ និងកន្លែងសម្លាប់វត្តកកោះ គណៈស្រុកឈ្មោះ ជីម បានរៀបចំផែនការសម្លាប់អ្នកទោស។ មុយ ចក់ បានប្រាប់ថា នៅពេលដែលគណៈស្រុក ជីម ជិះម៉ូតូសេអឺល៩០ ពណ៌ក្រហម ចូលមកកាន់វត្តកកោះម្តងៗ និងក្រោយពេលដែល ជីម ចេញទៅវិញ ប្រាកដជាមានអ្នកទោសមួយចំនួនត្រូវកងសន្តិសុខនាំទៅសម្លាប់ និងមួយចំនួនទៀតត្រូវនាំយកទៅសួរចម្លើយ ព្រមទាំងធ្វើទារុណកម្មធ្ងន់។ តុសួរចម្លើយស្ថិតនៅចម្ងាយតែ៥ម៉ែត្រប៉ុណ្ណោះពីរណ្តៅសាកសព។ ពេលសួរចម្លើយ ពុត បានបើកបញ្ជីមួយមើលថា តើឈ្មោះអ្នកទោសណាខ្លះដែលត្រូវសម្លាប់ និងឈ្មោះណាខ្លះដែលត្រូវទុក ព្រោះនៅក្នុងបញ្ជីនោះមានគូសប៊ិចក្រហម ឬសញ្ញាខ្វែងជើងក្អែកទៅលើឈ្មោះអ្នកដែលត្រូវសម្លាប់។ មុយ ចក់ បានបញ្ជាក់ថាឈ្មោះនៅក្នុងបញ្ជីដែលសមមិត្ត ពុត កាន់ជាប់ក្នុងដៃ សុទ្ធតែបានកត់បញ្ចូលតាមរបាយការណ៍របស់ប្រធានភូមិ ឬគណៈឃុំ មុនពេលបញ្ជូនអ្នកទាំងនោះមកកាន់មន្ទីរវត្តកកោះ ឬមន្ទីរ០៨។ បន្ទាប់មក បញ្ជីនេះត្រូវបញ្ជូនទៅកាន់មន្ទីរស្រុកដើម្បីពិនិត្យមើល។ សមមិត្ត ជីម ជាអ្នកពិនិត្យបញ្ជីនេះដោយផ្ទាល់ និងជាអ្នកគូសសញ្ញាខ្វែងជើងក្អែក ឬគូសប៊ិចក្រហមលើឈ្មោះមនុស្សដែលត្រូវសម្លាប់។ បន្ទាប់ពីពិនិត្យរួច ជីម បានបញ្ជូនបញ្ជីនេះមកកាន់មន្ទីរ០៨វិញ ដោយមានសមមិត្ត ស្រ៊ី អនុប្រធានមន្ទីរសន្តិសុខ ជាអ្នកកាន់កាប់បញ្ជី និងកងសន្តិសុខប្រចាំមន្ទីរ ជាអ្នកអនុវត្តការសម្លាប់អ្នកទោសដោយផ្ទាល់។ មុនពេលសម្លាប់អ្នកទោសទាំងអស់ត្រូវកងសន្តិសុខចងស្លាបសេក និងរុំមុខជិតឈឹង ហើយបញ្ជូនឱ្យទៅលុតជង្គង់ នៅមាត់រណ្តៅតែម្តង។ ការសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខវត្តកកោះបានប្រព្រឹត្តទៅស្ទើរតែរាល់ថ្ងៃ។ ក្នុងមួយថ្ងៃៗ មានអ្នកទោសស្លាប់ចាប់ពី៥០នាក់ ទៅ១០០នាក់។ មុយ ចក់ បានសន្និដ្ឋានថា ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ កងសន្តិសុខនៅមន្ទីរសន្តិសុខវត្តកកោះបានសម្លាប់អ្នកទោសអស់ប្រមាណ២ម៉ឺននាក់។ ទោះជាយ៉ាងណាក៏ដោយ អ្នកទោសមួយចំនួនដែលជាប្រជាជនមូលដ្ឋានត្រូវអង្គការលើកលែងទោស ហើយនៅរស់រហូតដល់បច្ចុប្បន្ននេះ ដូចជា មុយ ចក់ ព្រមទាំងមិត្តភក្តិប៉ុន្មាននាក់ទៀតរបស់គាត់។ មុយ ចក់ បាននិយាយរឿងរួចខ្លួនពីការស្លាប់របស់គាត់និងមិត្តភក្តិថា មកពីកងសន្តិសុខចាប់ "ច្រឡំឈ្មោះ"។

នៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខវត្តកកោះ លែងមានសកម្មភាពសម្លាប់មនុស្សទៀត ហើយ បន្ទាប់ពីកងសន្តិសុខ ប្រធាន និងអនុប្រធានមន្ទីរបានរត់យករួចខ្លួនចេញពីមន្ទីរសន្តិសុខអស់ទៅ។ ចំណែកអ្នកទោសដែលនៅសល់ពីស្លាប់ ក៏ចែកផ្លូវគ្នាវិលត្រឡប់ទៅរកគ្រួសាររៀងៗខ្លួនវិញ។

ព្រះតេជគុណ កែវ កុសល ព្រះជន្ម២៥ព្រះវស្សា បានឮតាមសង្ឃដីការបស់លោកគ្រូ ព្រះនាម សូរ សាត់ (សុគត) ថា ក្រោយឆ្នាំ១៩៧៩ ខាងក្នុងព្រះវិហារវត្តកកោះនៅមានស្នាមប្រឡាក់ឈាមលើកំរាលឥដ្ឋខាងមុខបល្ល័ង្កព្រះពុទ្ធបដិមាដែលបាក់បែកនៅឡើយ។ ចំណែកនៅតាមជញ្ជាំងព្រះវិហារទាំងសងខាងមានស្នាមចោះទម្លុះជញ្ជាំង ដើម្បីស៊កនុកដែកសម្រាប់ដាក់ខ្នោះកជើងអ្នកទោស។ រហូតមកដល់បច្ចុប្បន្ននេះ ស្នាមចោះទម្លុះទាំងនោះត្រូវបានប៉ះភ្ជិតវិញ។ ខ្នោះជាច្រើនដែលប្រជាជននាំគ្នារើចេញពីមន្ទីរឃុំឃាំងអ្នកទោស ត្រូវរដ្ឋអំណាចមូលដ្ឋានយកទៅដាក់តម្កល់ក្នុងបូជនីយដ្ឋានមួយ ស្ថិតនៅខាងកើតឆៀងខាងត្បូងព្រះវិហារវត្តកកោះ ជាមួយនឹងអដ្ឋិធាតុមួយចំនួនដែលប្រជាជនគាស់កាយពីរណ្តៅសាកសពជុំវិញបរិវេណវត្តនៅក្នុងឆ្នាំ១៩៨០។ ព្រះតេជគុណ កែវ កុសល មានសង្ឃដីកាថា ឆ្អឹងដែលគាស់រួចមានចំនួនស្មើនឹងមួយភាគប្រាំនៃឆ្អឹងទាំងអស់។

# រឿងព្រេងនិទានខ្មែរ

រឿងរ៉ាវផ្សេងៗគ្នា ដែលរៀបរាប់ដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបង្ហាញឱ្យដឹងថា ជាញឹកញយ ប្រជាជនត្រូវខ្មែរក្រហមយកទៅដាក់នៅតាមស្ថានីយរថភ្លើង ឬបង្ខំឱ្យធ្វើដំណើរតាមរថភ្លើង។ ការជម្លៀសតាមផ្លូវរថភ្លើងត្រូវធ្វើឡើងភ្លាមៗ ក្រោយពីថ្ងៃ១៧មេសា និងពេញមួយរបបខ្មែរក្រហម។ ប្រជាជនត្រូវជម្លៀសជាច្រើនសារ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ប្រជាជនដែលត្រូវជម្លៀស មិនបានដឹងពីទីកន្លែង និងមូលហេតុជាក់លាក់អំពីការជម្លៀសឡើយ។

ប្រជាជនភាគច្រើនដែលនៅខេត្តតាកែវ ភូមិភាគនិរតី ឬខេត្តស្វាយរៀង ឬទីក្រុងភ្នំពេញរាប់សែននាក់ត្រូវជម្លៀសទៅកាន់ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលស្ថិតនៅភូមិភាគពាយ័ព្យ "ដើម្បីបង្កបង្កើនផលស្រូវ"។

យើងបានឮ និងព្យាយាមស្រមៃពីការជម្លៀសដែលបានកើតឡើងចំពោះ ឪពុកម្តាយ ពូមីង ជីដូន ជីតា និងកូនៗតាមរយៈរថភ្លើង ដោយមិនបានដឹងថារថភ្លើងនឹងយកអ្នកទាំងនោះទៅណានោះទេ។ ប្រជាជនជម្លៀសបានធ្វើដំណើររយៈពេលដ៏វែង ជាមួយឥវ៉ាន់ផ្ទាល់ខ្លួនតែបន្តិចបន្តួច និងអាហារហូបចុកមិនគ្រប់គ្រាន់។

តើមានរឿងរ៉ាវអ្វីខ្លះ ដែលប្រជាជនជម្លៀសបាននិយាយគ្នាក្នុងពេលធ្វើដំណើរលើរថភ្លើងដ៏វែងឆ្ងាយ? តើប្រជាជនជម្លៀសបានឆ្លងកាត់ពេលវេលា និងបានធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់? តើប្រជាជនជម្លៀសបានធ្វើអ្វីខ្លះ ដើម្បីធានាថាកូនៗរបស់ខ្លួនមានអារម្មណ៍កក់ក្តៅ? រឿងព្រេងនិទានខ្មែរត្រូវនិពន្ធឡើង ដើម្បីចែករំលែកពីមាត់មួយទៅមាត់មួយ អស់រយៈពេលជាច្រើនសតវត្សរ៍។ រឿងព្រេងនិទានទាំងនោះមិនត្រឹមតែផ្តល់ជាមេរៀនក្នុងន័យសីលធម៌ប៉ុណ្ណោះទេ ថែមទាំងបានពន្យល់ពីទីតាំង ទេសភាព និងទិសដៅរបស់ផ្កាយដែលរះនៅលើមេឃដែរ។ នៅក្នុងពិព័រណ៍នេះ យើងមានរឿងព្រេងនិទានចំនួនពីរ ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិទាននៅពេលកំពុងធ្វើដំណើរតាមរថភ្លើង។ ការធ្វើដូចនេះអាចជួយដល់កូនៗរបស់ខ្លួនបានស្ងប់អារម្មណ៍ ក៏ដូចជាបានយល់ដឹងអំពីដំណើរផ្កាយរះ ដែលជួយឱ្យដឹងពីទិសដៅរថភ្លើងកំពុងធ្វើដំណើរឆ្ពោះទៅ។

## អាប៉ាង នាងតី

ក្នុងសម័យមួយនោះ នារដូវស្រូវទុំ អាប៉ាង ទៅដេកចាំស្រូវវាទាំងយប់ទាំងថ្ងៃ ដោយមានចាប៉ីយកទៅជាមួយផង។ វេលាថ្ងៃឡើងថែទាំស្រូវ ដល់ពេលយប់ទំនេរតែងដេញចាប៉ីហើយស្រែកច្រៀងផង។ លុះច្រៀងរាល់យប់ទៅ មានខ្មោចស្រីក្រមុំម្នាក់ ឮសូរចម្រៀងច្រៀងចាប៉ីពិរោះពេក ក៏ដើរទៅអង្គុយស្តាប់ក្រោមខ្ទម អាប៉ាង។ យូរបន្តិចទៅ អាប៉ាង ក្រឡេកទៅក្រោមផ្ទះ ឃើញខ្មោចដែលតំណែងខ្លួននោះអង្គុយអាំងភ្លើង អាប៉ាងសួរទៅថា "អាណាអង្គុយក្រោមខ្ទមនេះ?" មេខ្មោចប្រាប់ថា "ខ្ញុំ"។ អាប៉ាងថា "ប្រហែលជាខ្មោចទេ"។ មេខ្មោចឆ្លើយថា "ខ្មោចថាមិនខ្មោច"។ អាប៉ាងសួរថា "ហោងឯងឈ្មោះអី? មករកអ្វី?"។ មេខ្មោចថា "ខ្ញុំឈ្មោះ តី ខ្ញុំមកស្តាប់ចាប៉ី"។ អាប៉ាងថា "ឡើងមក! បើមកស្តាប់ចាប៉ី"។ មេខ្មោចឡើងទៅអង្គុយជិត អាប៉ាង ក៏ស្រលាញ់គ្នាយកជាប្តីប្រពន្ធទៅ។ ដល់រួចស្រូវ មេខ្មោចនោះ សួរទៅ អាប៉ាង ថា "ឥឡូវរួចស្រូវហើយ តើឯងព្រមយកអញឬទេ? បើឯងមិនយកអញៗនឹងកាច់កឯង"។ អាប៉ាង ឆ្លើយវិញថា "អញព្រមយក ប៉ុន្តែចាំអញដឹកស្រូវទៅទុកផ្ទះសិន"។ លុះ អាប៉ាង ដឹកស្រូវយកទៅទុករួចហើយ ក៏ត្រឡប់មកយកមេកន្តីនោះវិញ។ មេកន្តីក៏នាំ អាប៉ាង ទៅជម្រាបសួរពួកបងប្អូនខ្មោចទាំងប៉ុន្មាន រួចក៏នៅជាមួយគ្នាទៅ។

ប្រហែលជាងមួយខែ ពួកខ្មោចទាំងប៉ុន្មានបបួលគ្នា ព្រមទាំង អាប៉ាង ឱ្យទៅរកបាញ់សត្វមកធ្វើជាអាហារ។ អាប៉ាងក៏ទៅជាមួយនឹងពួកខ្មោចនោះ លុះទៅដល់កណ្តាលព្រៃដើមត្រថុក ដែលខ្មោចទាំងពួងសម្គាល់ថា ដើមឈើទាល បានប្រទះនឹងកង្កែបមួយ ខ្មោចទាំងនោះស្រែកថា "ប្រយ័ត្នវើយកនយើង! ដំរីធំណាស់ទៅហើយ!"។ អាប៉ាង ឮគេស្រែក

ថាដំរី ក៏ប្រឹងរកមើលមិនឃើញដំរីសោះ ឃើញតែកង្កែបលោតមកត្រង់មុខ អាប៉ាង ក៏ចាប់ដាក់ក្នុងថ្នក់សំពត់ទៅ។ ខ្មោចអស់នោះចេះតែស្រែកថា "ប្រយ័ត្នរើយដំរីស្តមួយធំណាស់" ហើយស្រែកសួរអាប៉ាងថា "ឃើញដំរីឬទេ?" អាប៉ាងស្រែកថា "មិនឃើញទេ!"។ ពួកខ្មោចក៏នាំគ្នាដើរមកដល់ជិត អាប៉ាង ហើយថា "ទៅ អាប៉ាង ទៅផ្ទះយើងរកសត្វមិនបាន"។ អាប៉ាង ថា "អញបានកង្កែបមួយ"។ ខ្មោចទាំងនោះសួរទៅ អាប៉ាង ថា "យ៉ាងដូចម្តេច អាប៉ាង កង្កែបនោះ? ឯងចែកឱ្យយើងរាល់គ្នាស៊ីផង"។ អាប៉ាង យកកង្កែបចេញពីថ្នក់ ហើយបង្ហាញទៅពួកខ្មោចនោះ។ ខ្មោចអស់នោះឃើញ ក៏នាំគ្នារត់ព្រោងព្រាតអស់ទៅ ហើយវាមានវាចាថា "ទុកប្តីមីកន្តីឱ្យនៅមិនបានទេ ព្រោះវាខ្លាំងពូកែណាស់ វាហ៊ានចាប់ដំរីយកទៅដាក់ក្នុងថ្នក់វា បើដូច្នេះយើងឱ្យ អាប៉ាង នេះនៅមិនបានទេ ឱ្យវាទៅវិញទៅ!" អាប៉ាង ក៏បានរួចខ្លួន ហើយត្រឡប់ទៅផ្ទះវិញ។

## ផ្កាយក្រពើ

*ផ្កាយបុណ្យកឋិន*

ជាយូរណាស់មកហើយ មានសេដ្ឋីម្នាក់ លួចយកទ្រព្យសម្បត្តិទៅកប់ទុកនៅមាត់ទឹកមុខផ្ទះ ដោយមិនប្រាប់ឱ្យអ្នកណាដឹងសូម្បីតែភរិយារបស់ខ្លួន។

ពេលសេដ្ឋីបាត់បង់ជីវិតទៅ ក៏បានមកពន្យល់សប្តិប្រាប់កន្លែងលាក់សម្បត្តិដល់ភរិយា និងសុំឱ្យបែងចែកទ្រព្យសម្បត្តិដែលគាស់បានទៅធ្វើបុណ្យ ដោយការធ្វើបុណ្យកឋិន ឧទ្ទិសបុណ្យកុសលទៅឱ្យខ្លួន។ ពេលវេលាកន្លងទៅ ភរិយារបស់សេដ្ឋីគិតថាគ្រាន់តែជាការយល់សប្តិយូរថ្ងៃទៅក៏ភ្លេច រហូតសេដ្ឋីទៅកើតជាក្រពើវិលវល់ក្បែរសាលាឆទានជានិច្ចរហូតអ្នកស្រុកនាំគ្នាល្បីពីរឿងចម្លែកនេះ។

ការបង្ហាញខ្លួនរបស់ក្រពើ និងពាក្យល្បីរបស់អ្នកស្រុក ធ្វើឱ្យភរិយាសេដ្ឋីនឹកដល់រឿងនៅក្នុងសុបិនឡើងមក ទើបឱ្យអ្នករាល់គ្នាទៅគាស់ទ្រព្យសម្បត្តិពីកន្លែងកប់នោះ។

គ្រប់គ្នាចម្លែកចិត្ត ពេលគាស់ឃើញហិបធំមួយ ពេលភរិយាសេដ្ឋីបើកហិបសម្បត្តិនោះមើល ក៏ឃើញមាសពេជ្រកែវកងជាច្រើន។ នាងក៏បែងចែកទ្រព្យសម្បត្តិមួយចំណែកទៅធ្វើបុណ្យកឋិនតាមដែលសេដ្ឋីត្រូវការ។

ក្នុងថ្ងៃហែកឋិន ខណៈដែលក្បួនទូកនាំអង្គកឋិនចេញពីច្រាំង ក្រពើសេដ្ឋីក៏ហែលនាំក្បួនទូកទៅ តែមិនទាន់ដល់វត្តផង ក៏អស់កម្លាំងមិនអាចហែលទៅមុខរួច។ ទើបភរិយាសេដ្ឋី និងអ្នកស្រុកជួយគ្នាគូររូបក្រពើលើក្រណាត់ចងជាប់ក្បាលទូកនាំក្បួន ដើម្បីជាសញ្ញាថា ក្រពើសេដ្ឋីបានទៅរួមធ្វើបុណ្យកឋិនក្នុងលើកនេះ។ ពេលក្រពើសេដ្ឋីស្លាប់ទៅ ផលបុណ្យពីការធ្វើបុណ្យកឋិនក៏បណ្តាលឱ្យកើតជា"ផ្កាយក្រពើ" បញ្ចេញរស្មីព្រិចៗនៅទិសខាងជើងអស់កាលជាយូររៀងមក។



រូបគំនូរវត្តលង្កា នៅទីក្រុងភ្នំពេញ។
គូរដោយ វិចិត្រករ អាសាសាស្រ្ត

# ការស្លាប់នៅក្នុងចលនាការជម្លៀសដោយបង្ខំ

## ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសាស្ត្រាចារ្យ : ជេមស៍ អេ ថាញណឺ

យើងស្គាល់មុខរបស់ជនរងគ្រោះនៅមន្ទីរស-២១ តាមរយៈរូបភាពស-ខ្មៅរបស់អ្នកទោស ដែលធ្លាប់ជាប់ឃុំឃាំង សួរចម្លើយ និងទទួលរងទារុណកម្ម។ រូបភាពរបស់ជនរងគ្រោះទាំងនោះនៅតែតាមលងបន្លាចយើងគ្រប់គ្នារាល់ពេលដែលយើងដើរចូលទៅក្នុងអាគារនៃអតីតមន្ទីរស-២១។ បច្ចុប្បន្ន មន្ទីរនេះត្រូវបានស្គាល់ថា ជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ នៅពេលដែលយើងធ្វើដំណើរទៅដល់វាលពិឃាតជើងឯក ហើយនាំគ្នាដើរយ៉ាងស្ងប់ស្ងាត់ឆ្លងកាត់រណ្តៅសាកសពជាច្រើន ធ្វើឱ្យយើងសញ្ជឹងគិតពីជីវិត និងការស្លាប់របស់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅវាលពិឃាតនេះ។ រូបភាពជនរងគ្រោះនៅទួលស្លែង និងបូជនីយដ្ឋានជើងឯក បានរំឭកអំពីអំពើហិង្សា ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។ រូបភាពខាងលើ បានបង្ហាញពីទង្វើនៃអំពើប្រល័យពូជសាសន៍។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងដោយខ្មែរក្រហម ដែលជាកំណើតនៃចលនា "មហាលោតផ្លោះមហាអស្ចារ្យ"។ លើសពីនេះទៅទៀត ខ្មែរក្រហមតែងតែនិយាយពាក្យមួយឃ្លាថា "កង់ប្រវត្តិសាស្ត្រចេះតែវិលទៅមុខ អ្នកដែលដើរមិនទាន់នឹងត្រូវកិនស្លាប់"។

ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ បុរស ស្ត្រី និងកុមារ ត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំទៅកាន់តំបន់ផ្សេងៗគ្នា។ ប្រជាជនប្រមាណពីរលាននាក់ ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ។ សម្រាប់ប្រជាជនមួយចំនួន ការជម្លៀសនេះ គឺជាការជម្លៀសលើកទីពីរ ដោយសារតែប្រជាជនទាំងនោះកាលពីមុនរបបខ្មែរក្រហមធ្លាប់បានផ្លាស់ទីលំនៅរបស់ខ្លួនម្តងរួចមកហើយ ដោយសារតែការហែកហួរនៃសង្គ្រាម។ ប្រជាជនកម្ពុជាត្រូវខ្មែរក្រហមបង្ខំឱ្យចេញពីផ្ទះ ឬស្រុកកំណើតរបស់ខ្លួន ដោយធ្វើដំណើរតាមរថយន្តរថភ្លើង រទេះគោ និងដោយថ្មើរជើង។ នៅពេលដែលមានការជម្លៀសដោយបង្ខំកើតឡើង ប្រជាជនមួយចំនួនបានបាត់បង់ជីវិតដោយសារតែកង្វះអាហារបរិភោគ ជំងឺ ការចាប់ និងការសម្លាប់។ ប្រជាជនកម្ពុជាត្រូវជម្លៀសជាបន្តបន្ទាប់ រសាត់ខ្ចាត់ខ្ចាយដូចខ្យល់ ទៅធ្វើការងារកសិកម្ម តាមឃុំ និងតាមសហករណ៍ ដូចជានៅខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ប៉ុន្តែសម្រាប់ខ្មែរក្រហមវិញ សូម្បីតែឈ្មោះក៏មិនអាចដាក់ដដែលបានដែរ។ ជំនួសមកវិញ ខ្មែរក្រហមបាន ប្រែក្លាយខ្លួនឯងទៅជាជនអានាមិក នៅទីកន្លែងមួយដែលមិនស្គាល់ឈ្មោះ និងទីតាំងមិនពិតប្រាកដ ដោយដើរតាមមនោគមវិជ្ជាតែមួយគត់របស់ខ្លួន។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ មនុស្សម្នាក់មិនបានរស់នៅកន្លែងតែមួយនោះទេ ពោលគឺមនុស្សម្នាក់អាចធ្វើការ និងស្លាប់នៅគ្រប់ទីកន្លែង។ ខ្មែរក្រហមបានបង្កើតការិយាធិបតេយ្យរបស់ខ្លួន ដោយបែងចែកជាភូមិភាគ និងតំបន់ព្រមទាំងបានដាក់ឈ្មោះ ភូមិភាគ ឬតំបន់ទាំងនោះដោយកំណត់ជាលេខ។ ជាលទ្ធផល ប្រជាជនប្រហែលជាកន្លះលាននាក់ ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ។ បុរស ស្ត្រី និងកុមារជាច្រើន បានហែលឆ្លងសមុទ្រនៃទុក្ខវេទនា។ ការឈឺចាប់របស់ប្រជាជនទាំងនោះ បានកើតឡើងគ្រប់ទីកន្លែង ដែលផ្ទុយនឹងទេសភាពវាលស្រែ និងព្រឹក្សព្រៃដ៏ខៀវស្រងាត់លើទឹកដីរបស់ប្រទេសកម្ពុជា។

ផ្លូវដែក គឺជាសមាសភាពសំខាន់មួយនៃការអនុវត្តរបស់ខ្មែរក្រហម។ ការជម្លៀសប្រជាជនរាប់សែននាក់ដោយបង្ខំត្រូវអនុវត្តឡើងពីភូមិភាគមួយទៅភូមិភាគមួយ ពីតំបន់មួយទៅតំបន់មួយ ជាពិសេសពីទីក្រុងទៅតំបន់ដាច់ស្រយាល។ ការជម្លៀសប្រជាជនដែលប្រព្រឹត្តិឡើងដោយខ្មែរក្រហម ខុសពីការជម្លៀសរបស់ណាហ្ស៊ីអាល្លឺម៉ង់ ឬការជម្លៀសនៅប្រទេសចិន "ការជម្លៀសឡើងលើភ្នំ និងការចុះទៅតាមទីជនបទ"។ រថភ្លើងរបស់ខ្មែរក្រហមបានទម្លាក់បុរស ស្ត្រី និងកុមារទៅតាមចំណតផ្សេងៗឱ្យទៅធ្វើការនៅតាមការដ្ឋាន និងសហករណ៍ផ្សេងៗ ដូចជានៅបឹងខ្នារ និងព្រៃស្វាយ ឬទៅកោះធំ និងបាត់ដំបង។

ដើម្បីធានាដល់ការគ្រប់គ្រងវិន័យ និងសណ្តាប់ធ្នាប់របស់កម្ពុជាប្រជាធិបតេយ្យ សហករណ៍តូចធំ ជាច្រើនត្រូវបង្កើតឡើង ដែលនៅក្នុងនោះមានប្រជាជនពីរាប់រយទៅ

រាប់ពាន់នាក់។ ប៉ុន្តែការបង្កើតនេះមិនបាននៅទ្រឹងមួយកន្លែងនោះទេ ពោលគឺ ការផ្លាស់ទីមនុស្សបានកើតឡើងជារៀងរាល់ថ្ងៃ។ មនុស្សម្នាក់ត្រូវខ្មែរក្រហមផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ទៅដកស្ទូងនៅតាមវាលស្រែ ទៅជម្រះព្រៃ ជីកប្រឡាយ និងទៅលើកទំនប់ទឹកជាដើម។ នៅក្នុងដំណើរការនេះ ជីវភាពរស់នៅតាមបែបលក្ខណៈគ្រួសារត្រូវបានបំបាត់។ ប្តីត្រូវបំបែកចេញពីប្រពន្ធ ឪពុកម្តាយបំបែកចេញពីកូនៗ បងបំបែកចេញពីប្អូន។ បើតាមការលើកឡើងរបស់ជនរងគ្រោះម្នាក់ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហមបានរំឭកថា "ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីស្រុកឱ្យទៅនៅក្នុងព្រៃ។ ខ្មែរក្រហមធ្វើបែបនេះក្នុងគោលបំណងបង្វែរគោលដៅរបស់យើង ដើម្បីងាយស្រួលគ្រប់គ្រងយើងទាំងអស់គ្នា"។ មនុស្សគ្រប់គ្នាត្រូវតែឆ្ពោះទៅមុខ ព្យាយាមធ្វើយ៉ាងណាឱ្យនៅពីមុខកង់ប្រវត្តិសាស្រ្ត បើមិនដូច្នោះទេ កង់ប្រវត្តិសាស្រ្តនឹងកិនស្លាប់ជាមិនខាន។ របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រល័យពូជសាសន៍ដែលមានចលនា។

នៅតាមសហករណ៍ និងការដ្ឋានការងារ រាល់សកម្មភាពការងារទាំងអស់របស់ស្រ្តីបុរស និងកុមារ ដែលស្ថិតក្រោមកំដៅសូរ្យសែង ឬព្យុះភ្លៀង តែងតែស្ថិតក្រោមការតាមដានរបស់អង្គការ។ កងទ័ពខ្មែរក្រហមតែងតែមានវត្តមាន និងតាមដានយ៉ាងតឹងរឹងនៅគ្រប់ទីកន្លែង ដូចជាឈរយាមនៅពេលមានការជម្លៀស ដើរត្រួតពិនិត្យតាមសហករណ៍ និងតាមការដ្ឋាន។ រាល់សកម្មភាព និងទស្សនៈទាំងឡាយណា ដែលខុសប្រក្រតីទោះតូចក្តីធំក្តីនឹងត្រូវខ្មែរក្រហមចាត់វិធានដាក់ទណ្ឌកម្មជាបន្ទាន់។ ជាក់ស្តែង ការឃុំឃាំងខ្លួននៅក្នុងមន្ទីរសន្តិសុខចំនួនប្រមាណជា២០០កន្លែងនៅទូទាំងប្រទេស ត្រូវធ្វើឡើងដូចៗគ្នា។

ការផ្លាស់ទីមានសារសំខាន់ ប៉ុន្តែការផ្លាស់ទីត្រូវខ្មែរក្រហមដាក់កំហិត។ ប្រជាជនគ្រប់រូបត្រូវតែបង្កបង្កើនផលស្រូវ ដែលជាការងារស្នូល។ ប៉ុន្តែទិន្នផលដែលទទួលបានត្រូវខ្មែរក្រហម នាំចេញបន្តទៅក្រៅប្រទេសដូចជា ប្រទេសចិន ប្រទេសយូហ្គោស្លាវីម៉ាដាហ្គាស្កា និង ហុងកុង ជាដើម។ ជាលទ្ធផល ប្រជាជនកម្ពុជារាប់សែននាក់ត្រូវទទួលរងការអត់ឃ្លាន និងកង្វះជីវជាតិ។ ជាងនេះទៅទៀត ប្រជាជនត្រូវធ្វើការជីកប្រឡាយ លើកទំនប់ ដឹកជញ្ជូនទឹកពីកន្លែងដែលសម្បូរ ទៅកន្លែងដែលខ្វះខាតទឹក បើកបររថយន្តដឹកទំនិញ ចែវទូក ឃ្វាលគោក្របី បើករថភ្លើង និងការងារដទៃជាច្រើនទៀត។ ពោលគឺ ប្រជាជនគ្រប់រូបត្រូវចូលរួមចំណែកជួយជំរុញឱ្យកង់ប្រវត្តិសាស្រ្តរបស់កម្ពុជាប្រជាធិបតេយ្យវិលទៅមុខមិនឈប់ឈរ ដែលនៅទីបញ្ចប់ឈានទៅដល់អំពើហិង្សាឃោរឃៅ។

ដូចដែលយើងគ្រប់គ្នាបានឃើញរណ្តៅសាកសពវាលពិឃាតជើងឯក និងរណ្តៅសាកសពរាប់ពាន់កន្លែងរាយប៉ាយទូទាំងប្រទេស ដែលរូបភាពឆ្លុះបញ្ចាំងពីសង្គមកម្ពុជានារបបខ្មែរក្រហម ហើយធ្វើឱ្យយើងគ្រប់គ្នានឹកឃើញរូបភាពជាប់ឃុំឃាំងចំពោះអ្នកទោសនៅគុកទួលស្លែង។ ចំពោះសោកនាដកម្មដែលបានកើតឡើង ទីតាំងដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ កង់ប្រវត្តិសាស្រ្តរបស់កម្ពុជាប្រជាធិបតេយ្យ ដែលជោគជាំដោយញើសឈាម និងទឹកភ្នែករបស់ប្រជាជនដែលគ្មានកំហុសរាប់លាននាក់ដែលបានបន្សល់ទុកនៅក្នុងរណ្តៅសាកសព គឺជាភស្តុតាងយ៉ាងច្បាស់ និងរឹងមាំមួយសម្រាប់បង្ហាញពីឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិដែលបានបង្កឡើងដោយខ្មែរក្រហម។

លោកសាស្រ្តាចារ្យជេមស៍ អេ ថាញណឺ គឺជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវទៅលើការបែងចែក នយោបាយ និងភូមិសាស្រ្តប្រជាជន ។ ការស្រាវជ្រាវថ្មីៗរបស់លោកសាស្រ្តាចារ្យពាក់ព័ន្ធទៅនឹងបញ្ហាសង្គ្រាម អំពើហិង្សា និងអំពើប្រល័យពូជសាសន៍។ លោកសាស្រ្តាចារ្យ ថាញណឺ មានចំណាប់អារម្មណ៍ទៅលើតំបន់អាស៊ីអាគ្នេយ៍។ កាលពីពេលថ្មីៗនេះ លោកសាស្រ្តាចារ្យបានធ្វើដំណើរទៅកាន់ ប្រទេសកម្ពុជា ហ្វីលីពីន វៀតណាម ឡាវ ថៃ ភូមា ម៉ាឡេស៊ី សាំងហ្គាពួរ ជប៉ុន និងចិន។ លោកសាស្រ្តាចារ្យបានសរសេរសៀវភៅចំនួន១៣ក្បាល ដែលក្នុងនោះសៀវភៅមួយរបស់លោក សាស្រ្តាចារ្យមានចំណងជើងថា "សង្គ្រាម អំពើហិង្សា និងប្រជាជន : អ្នកស្លាប់ត្រូវតែបានកត់ត្រាទុក" បានទទួលពានរង្វាន់ AAG Meridian Book Award សម្រាប់ស្នាដៃឆ្នើម ដែលបានចូលរួមចំណែកដល់ការសិក្សាស្រាវជ្រាវផ្នែកភូមិសាស្រ្ត។

# តើអ្នកអាចជួយព្យាបាលរបួសនៅក្នុងសង្គមកម្ពុជាឱ្យជាសះស្បើយតាមវិធីណា?

## សាស្ត្រាចារ្យ ចាយ៉ា រ៉េមជី ណូក្លាស ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រជាជនកម្ពុជាបានរង់ចាំអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីមើលឃើញមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តិ។ ប្រជាជនកម្ពុជាបានរង់ចាំអស់រយៈពេលជិត៣០ឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ទម្រាំអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០០៦។ នៅក្នុងចន្លោះពេលនៃការរង់ចាំនោះ មេដឹកនាំខ្មែរក្រហមបានវិវត្តទៅរកភាពចាស់ជរា និងមេដឹកនាំមួយចំនួនបានក្លាយជាអ្នកមានទ្រព្យធន។ ចំណែកឯប្រជាជនកម្ពុជាវិញនៅតែចងចាំមិនភ្លេចអំពីរឿងរ៉ាវទាំងឡាយ ដែលបានកើតនៅក្នុងរបបខ្មែរក្រហម ដែលខ្លួនធ្លាប់បានឆ្លងកាត់។ ប្រជាជនកម្ពុជាជាច្រើន មិនចង់រំឭកឡើងវិញនូវព្រឹត្តិការណ៍ដ៏គួរឱ្យភ័យខ្លាច ដែលបានកើតឡើងនៅក្នុងរយៈពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃនៃរបបខ្មែរក្រហមនោះទេ។ សូម្បីតែសាលារៀនក៏មិនបានបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនោះដែរ។ ប្រជាជនខ្មែរជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហមបានធំដឹងក្តីឡើងដោយពុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួនដូចៗគ្នា។

ការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាជំហានដ៏សំខាន់មួយដែលញ៉ាំងឱ្យប្រវត្តិសាស្ត្រខ្មែរក្រហមមានពន្លឺឡើង។ ជាក់ស្តែងសំណុំរឿង០០១នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានលាតត្រដាងពីស្ថានភាពមន្ទីរស-២១ ឬគុកទួលស្លែង។ សំណុំរឿង០០២ដំណាក់កាលទី១នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជា។ ការផ្សព្វផ្សាយជាសាធារណៈ និងកិច្ចខំប្រឹងប្រែងដើម្បីធានាថា ប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានបង្រៀននៅតាមសាលារៀន បានបង្កើននូវការយល់ដឹងរបស់ប្រជាជនកម្ពុជា អំពីប្រវត្តិអតីតកាលរបស់ប្រទេសកម្ពុជា។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានបើកទ្វាររបស់ខ្លួន ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះនៃរបបខ្មែរក្រហមបានចូលរួមនៅក្នុងដំណើរការផ្នែកច្បាប់។ ជនរងគ្រោះនៃរបបខ្មែរក្រហមបាននិយាយរៀបរាប់រឿងរ៉ាវរបស់ខ្លួននៅចំពោះមុខតុលាការ និងបានស្នើសុំឱ្យមានសំណងពីរបបខ្មែរក្រហម។ ជាសរុប ជនរងគ្រោះនៅសំណុំរឿងផ្នែកទីមួយនៃសំណុំរឿង០០២ បានស្នើសុំសំណងចំនួន១៣ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ សំណងដែលបានស្នើសុំទាំងនោះរួមមាន ការតាំងពិព័រណ៍ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ទិវាចងចាំរបស់ជាតិ ការសាងសង់បូជនីយដ្ឋានសាធារណៈនៅប្រទេសកម្ពុជា និងបារាំង មជ្ឈមណ្ឌលសហគមន៍សម្រាប់ការសិក្សាអំពីសន្តិភាព ការបោះពុម្ពរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការចងក្រងជំពូកមេរៀនស្តីអំពីការជម្លៀសដោយបង្ខំនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ កម្មវិធីព្យាបាលរបួសផ្លូវចិត្តដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និងការបោះពុម្ពផ្សាយសាលក្រមរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ដូចជាឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណើខាងលើនេះនឹងអាចជួយឱ្យប្រជាជនកម្ពុជាចងចាំ និងព្យាបាលរបួសពីអតីតកាល។

សំណើដែលបានរៀបរាប់ខាងលើ ជាដំណាក់កាលមួយក្នុងចំណោមដំណាក់កាលជាច្រើនសម្រាប់កិច្ចខំប្រឹងប្រែងក្នុងការចងចាំប្រវត្តិសាស្ត្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជាចំនួនតិចតួចនៅឡើយ ដែលចូលរួមស្តាប់សវនាការនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬបានយល់ច្បាស់ពីអ្វីដែលបានកើតឡើងនៅបន្ទប់សវនាការ។ ប៉ុន្តែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនទាន់អាចរកបានមូលនិធិគ្រប់គ្រាន់ ដើម្បីចំណាយលើការអនុវត្តគម្រោងសំណង ដែលបានរៀបរាប់ខាងលើនោះទេ។ ហេតុដូច្នេះប្រជាជនកម្ពុជាជំនាន់ក្រោយដែល៧០ភាគរយបានកើតក្រោយរបបខ្មែរក្រហម និងប្រជាជនជំនាន់មុន គប្បីសម្រេចចិត្តថា គួរធ្វើយ៉ាងណាដើម្បីពង្រឹងការយល់ដឹងរបស់ខ្លួនទាក់ទងនឹងប្រវត្តិសាស្ត្រជូរចត់របស់ខ្លួន ក៏ដូចជាកិច្ចខំប្រឹងប្រែងផ្សេងៗ ដើម្បីព្យាបាលរបួសកាលពីអតីតកាលឱ្យជាសះស្បើយ និងដើម្បីអភិវឌ្ឍប្រទេសជាតិ។

ការរៀបចំពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីរបបខ្មែរក្រហម គឺជាជំហានសំខាន់មួយ ក្នុងការអប់រំសាធារណជនអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ការចូលទស្សនារូបថតខ្សែវីដេអូ និងការស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អាចជួយធានាថាប្រវត្តិសាស្ត្រខ្មែរក្រហមនឹងមិនត្រូវបានបំភ្លេច។ ប្រសិនបើយើងគ្រប់គ្នាចងចាំទុកនូវសោកនាដកម្មដែលបានកើតឡើង នោះមានន័យថា យើងបានចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនោះកុំឱ្យកើតឡើងម្តងទៀតនៅលើទឹកដីនៃប្រទេសកម្ពុជា។ ប្រជាជនកម្ពុជាដែលមិនធ្លាប់ឆ្លងកាត់របបខ្មែរក្រហម នឹងមានការយល់ឃើញប្រសើរជាងប្រជាជនដែលធ្លាប់ឆ្លងកាត់របបនោះ ព្រមទាំងអាចជួយដល់ដំណើរការព្យាបាលរបួសពីអតីតកាលដែរ។ អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមអាចរៀបរាប់ប្រាប់អ្នកដទៃ ពីការចងចាំរបស់ខ្លួនទាក់ទងនឹងបទពិសោធន៍ឈឺចាប់កាលពីរបបខ្មែរក្រហម ដើម្បីចូលរួមរៀបចំសង្គមកម្ពុជាឡើងវិញ ដែលធ្លាប់បានហែកហួរដោយសារសង្គ្រាម។

ទន្ទឹមនឹងនេះដែរ មានកត្តាជាច្រើនដែលយើងគ្រប់គ្នាអាចចូលរួមចំណែក ដើម្បីព្យាបាលរបួសពីអតីតកាល និងឈានទៅរកអនាគតដ៏ភ្លឺស្វាង។

## ការជូនដំណឹងដល់សាធារណជន

ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសប្រជាជននៅក្នុងរបបខ្មែរក្រហម បានបង្ហាញពីទិដ្ឋភាពមួយនៃឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ តាមរយៈការទស្សនាពិព័រណ៍នេះ អ្នកនឹងអាចយល់ដឹងបន្ថែមអំពីហេតុផល និងផលប៉ះពាល់នៃការជម្លៀសមកលើប្រជាជនកម្ពុជា។ ទន្ទឹមនឹងនេះដែរ ប្រជាជនកម្ពុជាគួរស្វែងយល់បន្ថែមអំពីឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្ត និងស្វែងយល់បន្ថែមពីការឈឺចាប់របស់អ្នកដែលធ្លាប់រស់ក្នុងរបបខ្មែរក្រហម ព្រមទាំងមូលហេតុដែលខ្មែរក្រហមឡើងកាន់អំណាច ដើម្បទប់ស្កាត់កុំឱ្យក្រុមមនុស្សគ្រោះថ្នាក់ដទៃទៀតឡើងកាន់អំណាច។ គេហទំព័រមួយចំនួនបានផ្តល់ព័ត៌មានបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហមរួមមានវិទ្យាស្ថានស្លឹករឹត (www.cambodiasri.org) មជ្ឈមណ្ឌលឯកសារកម្ពុជា (www.dccam.org) គម្រោងឃ្លាំមើលការវិវត្តន៍របស់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម(www.cambodiatribunal.org) ជាដើម។

## ការប្រាស្រ័យទាក់ទងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត

ការឈឺចាប់ដែលប្រជាជនកម្ពុជាបានទទួលរងក្នុងរបបខ្មែរក្រហម ពិតជាពិបាកក្នុងការរៀបរាប់។ ទោះបីជាអ្នកមិនបានរស់នៅក្នុងរបបខ្មែរក្រហមក៏ដោយ ក៏ការចងចាំនៅក្នុងរបបខ្មែរក្រហមបានប៉ះពាល់ដល់ជីវិតអ្នកដទៃដែរ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែមានសាច់ញាតិ និងមិត្តភក្តិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ ការតាំងពិព័រណ៍ស្តីពីរបបខ្មែរក្រហមអាចជួយឱ្យអ្នកចាប់ផ្តើមការសន្ទនាជាមួយអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម អំពីការឈឺចាប់ដែលបានកប់ទុកក្នុងចិត្ត។ ការប្រាស្រ័យទាក់ទងគ្នាអាចជួយឱ្យអ្នករកវិធីជួយជនរងគ្រោះពីរបបខ្មែរក្រហមបាន។ អ្នកអាចជួបការលំបាកក្នុងការស្តាប់រឿងរ៉ាវរបស់ជនរងគ្រោះពីរបបខ្មែរក្រហម ប៉ុន្តែអ្នកអាចជួយជនរងគ្រោះទាំងនោះទៅរកសេវាព្យាបាលរបួសផ្លូវចិត្ត ឬការអប់រំផ្លូវចិត្តតាមបែបសាសនា។ អ្នកអាចជួយជនរងគ្រោះទាំងនោះស្វែងរកកម្លាំងចិត្ត និងផ្តល់ជំនួយផ្សេងៗ ដែលជនរងគ្រោះពីរបបខ្មែរក្រហមត្រូវការដើម្បីព្យាបាលរបួសផ្លូវចិត្ត។

## ការចូលរួមចំណែកក្នុងការងារផ្សេងៗ

បន្ទាប់ពីបានទស្សនាពិព័រណ៍ស្តីអំពីរបបខ្មែរក្រហម អ្នកពិតជាចូលរួមចំណែកក្នុងបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅដល់ប្រជាជនដទៃទៀត តាមរយៈការចែករំលែកព័ត៌មានដែលអ្នកទទួលបាននៅថ្ងៃនេះ ក៏ដូចជាព័ត៌មានដែលអ្នកអាចរកបាននៅក្នុងគេហទំព័រដែលបានរៀបរាប់ខាងលើជាមួយមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នក។ ប្រសិនបើអ្នកជាគ្រូបង្រៀន អ្នកអាចប្រើប្រាស់សៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)" និពន្ធដោយ ឌី ខាំបូលី ដើម្បីបង្រៀនអ្នកដទៃពីរបបខ្មែរក្រហម។ អ្នកអាចទាក់ទងជាមួយនឹងវិទ្យាស្ថានស្លឹករឹត (www.cambosiasri.org) ដើម្បីស្វែងយល់បន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម ឬដាក់ពាក្យធ្វើការងារស្ម័គ្រចិត្ត ដើម្បីចូលរួមចែករំលែកព័ត៌មានដល់អ្នកដទៃ។

## ការចងចាំអំពីកេរដំណែលប្រវត្តិសាស្ត្ររបស់កម្ពុជា

ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រដ៏យូរលង់ និងសម្បូរបែបដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា។ ប្រទេសកម្ពុជាមានកេរដំណែលវប្បធម៌ជាច្រើនដូចជា ប្រាសាទអង្គរវត្ត របាំបុរាណ និងរបាំប្រជាប្រិយ ដែលប្រជាជនកម្ពុជាគួរតែអបអរសាទរ។ ខ្មែរក្រហមបានព្យាយាមបំផ្លាញប្រពៃណី និងវប្បធម៌ដ៏សម្បូរបែបទាំងនេះ និងបានបំបិទសិទ្ធិប្រជាជនកម្ពុជា។ ដូច្នេះ អ្នកអាចចូលរួមក្នុងការព្យាបាលរបួសពីអតីតកាល និងស្តាប្រពៃណីវប្បធម៌របស់កម្ពុជាឡើងវិញ។

## ការរក្សាអនាគតកម្ពុជា

ចំណេះដឹងអំពីប្រវត្តិសាស្ត្រ អាចជួយទប់ស្កាត់ការប្រព្រឹត្តិកំហុសឆ្គងពីអតីតកាល និងឈានទៅរកអនាគតភ្លឺស្វាង។ អនាគតរបស់ប្រទេសកម្ពុជា ស្ថិតនៅក្នុងដៃរបស់អ្នក ក៏ដូចជាប្រជាជនកម្ពុជាគ្រប់រូប។ ឥឡូវនេះ កម្ពុជាគឺជាប្រទេសប្រជាធិបតេយ្យ។ ដូច្នេះ យើងគ្រប់គ្នាគួរតែមានការទទួលខុសត្រូវខ្ពស់។ យើងគ្រប់គ្នាត្រូវសិក្សាឱ្យបានច្បាស់លាស់ និងត្រិះរិះពិចារណាឱ្យបានល្អិតល្អន់មុនពេលបោះឆ្នោត។ តើបញ្ហាណាខ្លះដែលអ្នកគិតថាចាំបាច់ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរូបណាខ្លះ ដែលអ្នកគិតថាអាចជួយដោះស្រាយបញ្ហារបស់អ្នកបាន? ប្រជាជនគ្រប់រូបមានសិទ្ធិក្នុងការបោះឆ្នោត។ ដូច្នេះ យើងត្រូវតែអនុវត្តសិទ្ធិរបស់យើង។ ការចងចាំរបស់ប្រជាជនដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម គួរតែជាគោលគំនិតមួយក្នុងការជ្រើសរើសមេដឹកនាំប្រទេស។

សាស្ត្រាចារ្យ ចាយ៉ា រ៉ែមជី ណូក្លាស ជាសាស្ត្រាចារ្យផ្នែកច្បាប់ និងសហនាយកនៃវិទ្យាស្ថានច្បាប់អន្តរជាតិ និងគោលនយោបាយសាធារណនៅ Temple University's Beasley School of Law។ សាស្ត្រាចារ្យ ចាយ៉ា រ៉ែមជី ណូក្លាស គឺជាទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ២០០៧។ សាស្ត្រាចារ្យ ចាយ៉ា រ៉ែមជី ណូក្លាស បានសិក្សាស្រាវជ្រាវរឿងរ៉ាវជាច្រើនដែលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សអន្តរជាតិ យុត្តិធម៌អន្តរកាល ដោយផ្តោតលើដំណើរការ និងការបង្កើតស្ថាប័ន។ សាស្ត្រាចារ្យ ចាយ៉ា រ៉ែមជី ណូក្លាស បាននិពន្ធសៀវភៅជាច្រើន ដែលទាក់ទងនឹងយុត្តិធម៌អន្តរកាលនៅប្រទេសកម្ពុជា។ នៅពេលថ្មីៗនេះ សាស្ត្រាចារ្យ ចាយ៉ា រ៉ែមជី ណូក្លាស បានសហការណ៍ជាមួយ សាស្ត្រាចារ្យ ចន ឆរឆីអារី និពន្ធសៀវភៅមួយនិយាយអំពីបទពិសោធន៍របស់ប្រទេសកម្ពុជាទាក់ទងនឹងការពិត និងការផ្សះផ្សា ដែលបានបោះពុម្ពផ្សាយនៅក្នុង 19 Buffalo Human Right Law Review(2012) និងស្នាដៃជាច្រើនផ្សេងទៀត។

# ការចងចាំនៃការជម្លៀសដោយបង្ខំ

ដោយ ហ៊ុយ សម្ផស្ស, ហាថសុន ម៉ាកវេន និង ផាត កុសល ក្រុមការងារអន្តរជាតិសិក្សាលើប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍នៃសាកលវិទ្យាល័យរ៉ាត់ហ្គឺ

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៦ ប៉ុល ពត បានប្រកាសថាមាន "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជួរបក្ស" ដូច្នេះត្រូវតែមានការ "តាមដាន" និងដាក់កម្រិតដល់ការធ្វើបន្សុទ្ធកម្ម ដើម្បីបដិវត្តន៍ខ្មែរក្រហម។ ខ្មែរក្រហមព្រមានថា "គ្មានមន្ទីរពេទ្យណាអាចព្យាបាលជំងឺនេះបានទេ"។ ដូច្នេះវិធីដ៏ល្អប្រសើរសម្រាប់អង្គការមានតែ"កម្ចាត់"ប្រភេទជននោះចោល។ ខ្មែរក្រហមជារឿយៗតែងតែប្រើពាក្យពេចន៍ បន្ទរបន្ថយទម្ងន់នៃទង្វើរបស់ខ្លួន ដោយប្រៀបធៀបទៅនឹងអ្វីដែលខ្លួនបានសន្មតថាជា ជំងឺសតិអារម្មណ៍។ ពាក្យស្លោកមួយដែលខ្មែរក្រហមបានប្រើ "ត្រូវតែកម្ចាត់ចោលឱ្យអស់នូវខ្មាំងរូបិយ និងខ្មាំងអរូបិយ ខ្មាំងសតិអារម្មណ៍" ដូចដែលខ្មែរក្រហមបានព្យាយាមបង្វែងដានជនប្រឆាំងនឹងបដិវត្តន៍របស់ខ្លួនតាមរយៈការស្វែងរករោគវិនិច្ឆ័យលើ "ការចងចាំរបស់ខ្មាំង"ដែលជារោគរ៉ាំរ៉ៃ។

នៅពេលដែលខ្មែរក្រហមទទួលបានជោគជ័យ និងដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាមៗនោះ ខ្មែរក្រហមចាប់ផ្តើមបង្ខំប្រជាជន និងជនភៀសខ្លួនដែលរស់នៅក្នុងទីក្រុងឱ្យចាកចេញពីទីក្រុងទៅនៅតាមទីជនបទ។ ខ្មែរក្រហមបានប្រកាសថា "បងប្អូនប្រុសស្រីទាំងឡាយអង្គការស្នើសុំឱ្យបងប្អូនចាកចេញពីទីក្រុងភ្នំពេញក្នុងរយៈពេល៣ថ្ងៃ ព្រោះអង្គការត្រូវការបោសសម្អាតខ្មាំងសម្ងំលាក់ខ្លួនចេញឱ្យអស់។ សហរដ្ឋអាមេរិកមិនអាចភ្លេចនូវភាពបរាជ័យរបស់ខ្លួនបាននោះទេ ការចាកចេញនេះក៏ដើម្បីជៀសវាងការទម្លាក់គ្រាប់បែកបេ-៥២របស់សហរដ្ឋអាមេរិកដែរ"។ ខ្មែរក្រហមបានអះអាងថា ការចាកចេញនេះមានរយៈពេលខ្លី ហើយប្រជាជននឹងត្រឡប់ទៅលំនៅស្ថានរបស់ខ្លួនវិញក្នុងពេលឆាប់ៗ ដូច្នេះប្រជាជនមិនចាំបាច់នាំយករបស់របរអ្វីច្រើនទៅជាមួយនោះទេ។ ផ្ទុយទៅវិញការនាំយករបស់របរមានតម្លៃនឹងត្រូវដកហូត។ ទាំងក្នុងពេល និងក្រោយពេលជម្លៀស ខ្មែរក្រហមស្នើសុំឱ្យប្រជាជនបោះបង់ចោលអ្វីដែលជាភស្តុតាងសម្គាល់អត្តសញ្ញាណរបស់ខ្លួន ដូចជា "រូបថត ឬវត្ថុនានាដែលមានជាប់នៅនឹងខ្លួនអាចត្រូវបានចោទថាជាជំងឺដែលសល់ពីការចងចាំ"។ នេះជាការបកស្រាយរបស់អ្នករស់រានមានជីវិតម្នាក់ឈ្មោះ ម៉ម ប៊ុតធីតា។ ប៊ុតធីតា បានពន្យល់ទៀតថា "សំបុត្រដែលផ្ញើមកពីឪពុករបស់ខ្ញុំ ត្រូវចាត់ទុកថាបានបង្ហាញពីភាពមិនប្រក្រតីនាពេលអតីតកាល"។

ការផ្លាស់ប្តូរតួនាទី និងកាតព្វកិច្ចរបស់ប្រជាជនជិត២លាននាក់ ដែលត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយយកគំរូតាមលទ្ធិម៉ៅនិយម ត្រូវចាត់ទុកជាសម័យដ៏មហារុងរឿងមហាលោតផ្លោះ។ ប្រជាជនត្រូវធ្វើដំណើរយ៉ាងឆ្ងាយសន្លឹមដោយថ្មើរជើង រថភ្លើង រទេះគោ រថយន្តដឹកទំនិញ ត្រាក់ទ័រ និងទូកនេសាទនានា ដោយមិនគិតពីអាយុ ឬស្ថានភាពសុខភាពនោះទេ។ សូម្បីតែនៅតាមមន្ទីរពេទ្យនានា ក៏ពុំមានអ្នកជំងឺស្នាក់នៅដែរ។ ភស្តុតាងជាច្រើនបានបង្ហាញថា ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានចូលរួមដោយផ្ទាល់ក្នុងការសម្រេចចិត្តជម្លៀសប្រជាជនដោយបង្ខំ។ ទន្ទឹមនឹងគ្នានេះដែរ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ភូមិភាគផ្សេងៗ ត្រូវតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម លើកយកមកជំនុំជម្រះក្នុងសំណុំរឿង០០២ផ្នែកទីមួយ ។

ជាក់ស្តែង ខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំ ដោយពុំមានផ្តល់ជំនួយ ឬមធ្យោបាយអ្វីទាំងអស់ ដែលធ្វើឱ្យអ្នកដែលត្រូវជម្លៀសទទួលរងនូវភាពអមនុស្សធម៌ជាច្រើនរួមមាន បែកបាក់ក្រុមគ្រួសារ បាត់ខ្លួន ជំងឺ ស្រេកឃ្លាន វាយដំ អំពើហឹង្សាផ្លូវភេទ និងសម្លាប់។ ការកំណត់ក្រុមមនុស្ស និងការធ្វើទុក្ខបុកម្នេញក្រុមមនុស្សនោះកើតឡើងជាបន្តបន្ទាប់ នៅក្នុងអំឡុងពេលជម្លៀសដោយបង្ខំ។ ខ្មែរក្រហមបានបែងចែកប្រជាជនជាពីរ

ក្រុមដាច់ដោយឡែកពីគ្នា គឺប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ ប្រជាជនថ្មី ឬ"ប្រជាជន ១៧មេសា" ជាអតីតប្រជាជនមកពីទីក្រុង។ ចំណែកឯប្រជាជនមូលដ្ឋាន គឺជាប្រជាជនចាស់ ដែលរស់នៅតាមភូមិឃុំ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល។ អ្នករាជការក្នុងរបបសាធារណរដ្ឋខ្មែរអ្នករស់នៅទីក្រុង ជនជាតិចាម ជនជាតិភាគតិច ដូចជាវៀតណាមនិងចិន ព្រមទាំងព្រះសង្ឃ និងដូនជី ក៏ជាក្រុមមនុស្សដែលត្រូវបែងចែកសម្រាប់យកទៅអប់រំដែរ"។ គួរបញ្ជាក់ដែរថា អ្នកដែលរស់រានជីវិតចេញពីរបបខ្មែរក្រហមទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត និងផ្លូវកាយរហូតដល់សព្វថ្ងៃ។

បើយោងតាមវិធានផ្ទៃក្នុង មាត្រាទី២៣នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានសិទ្ធិប្តឹងទាមទារ និងទទួលបានសំណងសមូហភាព និងផ្លូវចិត្តតែប៉ុណ្ណោះ។ នៅក្នុងសំណុំរឿង០០២ផ្នែកទីមួយ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសំណងសមូហភាព និងផ្លូវចិត្តចំនួន១៣។ ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការស្វែងរកយុត្តិធម៌មានសារសំខាន់ណាស់ ដែលមិនត្រឹមតែជាតំណាងឱ្យជនរងគ្រោះដទៃទៀតនោះទេ ថែមទាំងលើកស្ទួយដល់ការជួសជុល និងផ្សះផ្សានៅក្នុងសហគមន៍។ ការដាក់តាំងពិព័រណ៍អចិន្ត្រៃយ៍ ស្តីអំពីការជម្លៀសដោយបង្ខំ នៅតាមសារមន្ទីរខេត្ត ដោយបង្ហាញពីរឿងរ៉ាវរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ប្រវត្តិភូមិ បូជនីយដ្ឋាន មន្ទីរសន្តិសុខ នឹងឆ្លុះបញ្ចាំងអំពីការចងចាំនៃអំពើប្រល័យពូជសាសន៍ និងការអប់រំដល់ក្មេងៗជំនាន់ក្រោយអំពីទិដ្ឋភាពនានាដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

ហ៊ុយ សម្ផស្ស កំពុងសិក្សាថ្នាក់បណ្ឌិត លើមុខជំនាញកិច្ចការសកល នៅសាកលវិទ្យាល័យរ៉ាត់ហ្គឺ សហរដ្ឋអាមេរិក និងជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគម្រោងការអប់រំអំពីអំពើប្រល័យពូជសាសន៍។ ហាចសុន ម៉ាករេន កំពុងសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យរ៉ាត់ហ្គឺ ផ្នែកភូមិសាស្ត្រ។ ផាត កុសល គឺជាជំនួយការសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយនៃសាកលវិទ្យាល័យប្រ៊ូកលីន និងជាអតីតនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០។ អ្នកទាំងបីរូបនេះ ជាសមាជិកគណៈកម្មាធិការបង្គោលរបស់ក្រុមការងារអន្តរជាតិសិក្សាអំពីប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍ នៃសាកលវិទ្យាល័យរ៉ាត់ហ្គឺ ដែលជាផ្នែកមួយនៃដំណើរការភាពជាដៃគូរវាងមជ្ឈមណ្ឌលសិក្សាអំពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស នៃសាកលវិទ្យាល័យរ៉ាត់ហ្គឺ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។



ស្ថានីយរថភ្លើងកុមារាជា នៅខេត្តតាកែវ ជាទីចំណតដែលខ្មែរក្រហមជម្លៀសប្រជាជនពីទិសទក្សិណទៅទិសឧត្តរ
នៅក្នុងរបបខ្មែរក្រហម។ រូបថត ៖ សេង គន្ធី



# រូបថត

មុនរបបខ្មែរក្រហម



ម៉ុក ស៊ិនហៀង និងម្តាយ ព្រមទាំងក្រុមគ្រួសារ។




ម៉ុក សិនហៀង (រូបទីពីររាប់ពីខាងស្ដាំ) និងប្អូនស្រី។





(រូបខាងឆ្វេង) ម៉ុក លាន ជាឪពុករបស់ ម៉ុក ស៊ិនហៀង។ (រូបខាងស្តាំ) បងប្អូនជីដូនមួយរបស់ ម៉ុក ស៊ិនហៀង និង ម៉ុក ស៊ិនអ៊ី ថតនៅសួនផ្កាទួលគោក។





(រូបខាងឆ្វេង) ប៊ុន អៀន កាលពីនៅក្មេង ថតជាមួយមិត្តភិក្ត នៅខេត្តកំពង់ចាម ឆ្នាំ១៩៣៨។
(រូបខាងស្តាំ) ប៊ុន អៀន និង ប៊ុត ជូន ថតនៅផ្ទះក្រោយថ្ងៃរៀបការ នៅខេត្តកំពង់ចាម ឆ្នាំ១៩៤០។





(រូបខាងឆ្វេង) ខៀវ នឹម (ជួរខាងមុខ) និង ខៀវ នូវ (ដៃនៅលើចង្កេះ)។
(រូបខាងស្តាំ) រូបថត គង់ ចំរើន ជាមួយនឹងមីង នូ ថា (អង្គុយខាងឆ្វេង)
និង នូ បាត ព្រមទាំង បងប្អូនជីដូនមួយ (អង្គុយខាងមុខ)។





(រូបខាងឆ្វេង) ឡាម សំ ជាមួយកូន៧នាក់ ក្នុងចំណោមកូនទាំង១៣នាក់របស់គាត់ ថតនៅភ្នំពេញ ឆ្នាំ១៩៧១។ (រូបខាងស្តាំ) រូបថត ប៊ុត ចាន់មារ៉ាឌី កាលពីអាយុ៩ឆ្នាំ ថតនៅខេត្តកំពង់ចាម ឆ្នាំ១៩៥៩។





(រូបខាងឆ្វេង) ទេព គីមទ្រី និង ទេព ស៊ុយអៀង ថតក្រោយថ្ងៃរៀបការមួយខែ។ (រូបខាងស្តាំ) រូបថត ចាច់ កឹម និងប្រពន្ធ ពៅ ភិរុណ ព្រមទាំងកូនប្រុស ថតនៅនៅខេត្តបាត់ដំបង ឆ្នាំ១៩៧៣។





(រូបខាងឆ្វេង) រូបថត ទុន ឈុំ និងក្រុមគ្រួសារ។ (រូបខាងស្តាំ) លោក សាន សុខ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២ នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។



ពិធីរៀបអាពាហ៍ពិពាហ៍បងស្រីរបស់លោក ឆាំង យុ ឈ្មោះ កែវ ទិត្យសុរិយ៉េ និងលោក អ៊ុង សុន្ទរៈ នៅឆ្នាំ១៩៦៩។ លោក ឆាំង យុ អង្គុយនៅជ្រុងខាងឆ្វេងខាងលើ ជាមួយបងប្អូនជីដូនមួយរបស់គាត់ ឈ្មោះ កែវ សាវារី ដែលបានស្លាប់ដោយសារការអត់អាហារនៅក្នុងរបបខ្មែរក្រហម។ បុរសដែលស្លៀកពាក់សំលៀកបំពាក់ពណ៌ស ឈ្មោះ ជ័យ ឥន្ទ ជាអ្នកជិតខាងរបស់លោក ឆាំង យុ។ លោក ជ័យ ឥន្ទ ធ្លាប់បម្រើការជាមេបញ្ជាការប៉ូលីសប្រចាំខេត្តកំពង់ចាម។ ជ័យ ឥន្ទ និងប្រពន្ធត្រូវបានខ្មែរក្រហមសម្លាប់។ ស្ត្រីចាស់ដែលនៅក្រោយគូស្វាមីភរិយាទាំងពីរ គឺជាជីទួតរបស់លោក ឆាំង យុ។ គាត់បានស្លាប់ ដោយសារជំងឺចាស់ជរា។ បុរសដែលស្លៀកសំលៀកបំពាក់ខ្មៅ ពាក់វ៉ែនតា និងនៅពីក្រោយលោក ជ័យ ឥន្ទ គឺជាឪពុកមារបស់លោក ឆាំង យុ ឈ្មោះ សាគូ សាផុន។ គាត់ត្រូវបានខ្មែរក្រហមសម្លាប់។ ប្រភព : បណ្ណសាររបស់ក្រុមគ្រួសារលោក ឆាំង យុ។



ប្រជាជនកំពុងលើកទំនប់ទឹក និងប្រព័ន្ធប្រឡាយទឹក។



បុរស និងស្ត្រីកំពុងរែកដីនៅក្នុងរបបខ្មែរក្រហម។ រូបថតនេះថតនៅក្នុងពេលទស្សនកិច្ចរបស់កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ឬគណៈប្រតិភូបរទេស។ រាល់ពេលដែលមានកម្មាភិបាលជាន់ខ្ពស់ ឬគណៈប្រតិភូបរទេសធ្វើដំណើរទស្សនកិច្ច ប្រជាជនតម្រូវឱ្យស្លៀកពាក់ស្អាតបាត។ ពេ លខ្លះប្រជាជនត្រូវខ្មែរក្រហមចែកក្រមាឱ្យបណ្ដោះអាសន្ន នៅពេលមានដំណើរទស្សនកិច្ចរបស់កម្មាភិបាលជាន់ខ្ពស់ ឬគណៈប្រតិភូបរទេស។ មិនតែប៉ុណ្ណោះ ប្រជាជនត្រូវបានបង្គាប់ឱ្យសើចដាក់ម៉ាស៊ីនថត និងកម្មាភិបាល ឬគណៈប្រតិភូបរទេស។





(រូបខាងឆ្វេង) មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកំពុងជិះរថភ្លើង។ (រូបខាងស្តាំ) កម្មាភិបាលរថភ្លើងជំទង់កំពុងជម្លៀសប្រជាជនកម្ពុជារាប់សែននាក់ពីគ្រប់តំបន់ទៅកាន់ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា ដូចជា ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ជាដើម។



ប្រជាជនកំពុងលើកទំនប់ទឹកនៅតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម។  នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបង្ខំឱ្យធ្វើការងារពលកម្ម ដើម្បីសាងសង់ទំនប់ទឹក ជីកប្រឡាយ និងធ្វើស្រែ។



ប្រជាជនកម្ពុជាកំពុងជីកប្រឡាយទឹកនៅជាយក្រុងភ្នំពេញនៅក្នុងរបបខ្មែរក្រហម។ ប្រជាជនគ្រប់រូប ត្រូវតែគោរពបញ្ជារបស់ខ្មែរក្រហម។ ខ្មែរក្រហមបានប្រមូលប្រជាជនជាច្រើនធ្វើការងារពលកម្ម ដើម្បីបង្កើនទិន្នផលស្រូវនៅក្នុងប្រទេស។

 

(រូបខាងឆ្វេង) បុរស និងស្ត្រីវ័យកណ្តាលកំពុងរែកដីនៅក្នុងការដ្ឋានលើកទំនប់ទឹកនៅក្នុងរបបខ្មែរក្រហម។ (រូបខាងស្តាំ) បុរស និងស្ត្រីកំពុងធ្វើការលើកទំនប់ "១មករា" នៅស្ទឹងជីនិត ខេត្តកំពង់ធំ។ រូបថតនេះបង្ហាញពីភាពមមាញឹករបស់ប្រជាជនកម្ពុជាក្នុងការធ្វើការងារយ៉ាងសកម្ម នៅក្រោមកំដៅព្រះអាទិត្យដ៏ក្តៅហែង។ រូបនេះថតនៅពេលដែល អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ធ្វើដំណើរទស្សនកិច្ចទៅកាន់ការដ្ឋានលើកទំនប់។





(រូបខាងឆ្វេង) កុមារកំពុងលីសម្ភារៈសម្រាប់ធ្វើស្រែទៅកាន់ការដ្ឋានការងារ។ ជាទូទៅ កុមារ និងក្មេងជំទង់ត្រូវខ្មែរក្រហមប្រមូលផ្តុំដាក់នៅក្នុងកងដោយឡែក ដើម្បីបំពេញការងារពលកម្ម និងអប់រំ។ ភាគច្រើនកុមារ និងក្មេងជំទង់ទាំងនោះត្រូវខ្មែរក្រហមវាយដំ និងស្លាប់ដោយសារការអត់អាហារ ជំងឺ និងភាពឯកា។ កុមារ និងក្មេងជំទង់ទាំងនោះត្រូវខ្មែរក្រហមបំបែកចេញពីក្រុមគ្រួសារអស់រយៈពេលរាប់ឆ្នាំ។ កុមារ និងក្មេងជំទង់ខ្លះ បានបែកពីឪពុកម្តាយរបស់ខ្លួនជារៀងរហូត។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវផ្តួលរំលំនៅឆ្នាំ១៩៧៩ នៅប្រទេសកម្ពុជាមានកុមារកំព្រាប្រមាណ២០០០០០នាក់។ កុមារ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនមិនបានដឹងពីរឿងរ៉ាវ ដែលបានកើតឡើងចំពោះឪពុកម្តាយរបស់ខ្លួននោះទេ។ (រូបខាងស្តាំ) ទិដ្ឋភាពនៅក្នុងរោងបាយរួម។



អៀង សារី ជាមួយនឹងគណៈប្រតិភូចិន ចុះត្រួតពិនិត្យការដ្ឋានផ្លូវដែក នៅក្នុងអំឡុងពេលជម្លៀសប្រជាជនដោយបង្ខំនៅចុងឆ្នាំ១៩៧៥។



ផ្សារមួយក្នុងចំណោមផ្សារជាច្រើន ដែលបានបង្កើតឡើងជាលើកដំបូងក្នុងប្រទេសកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ។ រូបថតនេះបង្ហាញពីផ្សារមួយនៅស្រុកកោះធំ ខេត្តកណ្តាល នៅឆ្នាំ១៩៨០ នៅក្បែរព្រំដែនប្រទេសវៀតណាម។ រូបិយប័ណ្ណមិនទាន់ត្រូវគេបោះពុម្ពជាផ្លូវការនៅឡើយទេ។ ប្រជាជនប្រើប្រាស់ការដោះដូរទំនិញ ដើម្បីប្តូរយកអាហារ របស់របរដែលខ្លួនចង់បាន។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនជាស្ត្រី។ ចាប់តាំងពីពេលនោះមក ស្ត្រីទាំងនោះបានក្លាយទៅជាកម្លាំងទ្រទ្រង់ពីក្រោយការកសាងប្រទេសកម្ពុជាឡើងវិញ ដែលមានដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងស្មារតី។



ផ្សារមួយក្នុងចំណោមផ្សារជាច្រើន ដែលបានបង្កើតឡើងជាលើកដំបូងក្នុងប្រទេសកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ។ រូបថតនេះបង្ហាញពីផ្សារមួយនៅស្រុកកោះធំ ខេត្តកណ្តាល នៅឆ្នាំ១៩៨០ នៅក្បែរព្រំដែនប្រទេសវៀតណាម។ រូបិយប័ណ្ណមិនទាន់ត្រូវគេបោះពុម្ពជាផ្លូវការនៅឡើយទេ។ ប្រជាជនប្រើប្រាស់ការដោះដូរទំនិញ ដើម្បីប្តូរយកអាហារ របស់របរដែលខ្លួនចង់បាន។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនជាស្ត្រី។ ចាប់តាំងពីពេលនោះមក ស្ត្រីទាំងនោះបានក្លាយទៅជា កម្លាំងទ្រទ្រង់ពីក្រោយការកសាងប្រទេសកម្ពុជាឡើងវិញ ដែលមានដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងស្មារតី។

 

(រូបខាងឆ្វេង) បព្វជិត និងព្រះសង្ឃកំពុងប្រារព្ធពិធីបុណ្យតាមបែបព្រះពុទ្ធសាសនានៅចំពោះមុខអដ្ឋិធាតុជនរងគ្រោះ នៃរបបខ្មែរក្រហម។ នៅក្នុងព្រះពុទ្ធសាសនា អ្នកដែលបានស្លាប់ដោយអំពើហិង្សានឹងពិបាករកកន្លែងចាប់ជាតិ។ ដូច្នេះ ពិធីបុណ្យតាមបែបព្រះពុទ្ធសាសនាត្រូវបានប្រារព្ធឡើង ដើម្បីឧទ្ទិសកុសលដល់ជន ដែលបានស្លាប់បានទៅកាន់សុគតិភព។ (រូបខាងស្តាំ) ឆ្អឹង និងលលាដ៍ក្បាលរបស់ជនរងគ្រោះ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ត្រូវបានអាជ្ញាធរមូលដ្ឋានប្រមូលដាក់នៅក្នុងអាគារសាលារៀន ផ្ទះ និងខ្ទមដែលគេបោះបង់ចោល។ រូបភាពនេះបានបង្ហាញ អំពីអដ្ឋិធាតុរបស់ជនរងគ្រោះ ដែលបានប្រមូលមកទុកដោយគ្មានការថែរក្សា។ កន្លែងនេះ គឺជាកន្លែង សម្រាប់សាច់ញាតិជនរងគ្រោះមកធ្វើបុណ្យឧទ្ទិសកុសលដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។




នៅក្នុងរបបខ្មែរក្រហម ការសម្លាប់បានកើតឡើងស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា។ ឆ្អឹង និងលលាដ៍ក្បាលជាច្រើនបាននៅរាយប៉ាយគ្រប់ទីកន្លែង។ ប្រជាពលរដ្ឋភាគច្រើនបានគាស់រណ្តៅសាកសព ដើម្បីធ្វើបុណ្យជូនសាច់ញាតិ ដែលបានស្លាប់។ ទន្ទឹមនឹងនេះដែរ បូជនីយដ្ឋានជាច្រើនត្រូវកសាងឡើងសម្រាប់ឧទ្ទិសកុសលដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។



ជនរងគ្រោះពីរបបខ្មែរក្រហមចូលរួមប្រជុំជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីសិទ្ធិចូលរួមជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅខេត្តកំពង់ធំ នៅឆ្នាំ២០០៩។





(រូបខាងឆ្វេង) ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជួបជុំគ្នានៅទីក្រុងភ្នំពេញ ដើម្បីជ្រើសរើសមេធាវីតំណាងរបស់ខ្លួន នៅឆ្នាំ២០១០។ (រូបខាងស្តាំ) រូបថតអាគារតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ អាគារនេះត្រូវសាងសង់ និងរចនាឡើងជាសាលមហោស្រពសម្រាប់រាជអគ្គបញ្ជាការដ្ឋានកងទ័ព។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានជួលឱ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅឆ្នាំ២០០៦។ សាលនេះអាចផ្ទុកមនុស្សបាន ៥៥០នាក់។




ទិដ្ឋភាពខាងក្នុងបន្ទប់សវនាការនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលការិយាល័យនីមួយៗបម្រើការដោយបុគ្គលិកជាតិ និងអន្តរជាតិ។

# តើប្រទេសកម្ពុជាដែលធ្លាប់ជាវាលពិឃាតអាចផ្សះផ្សាបានដែរឬទេ ?

ថែរក្សាកេរដំណែលវាលពិឃាត ៖ ផែនទីឧក្រិដ្ឋកម្មខ្មែរក្រហម (ប្រល័យពូជសាសន៍) ទីតាំងសម្លាប់ មន្ទីរសន្តិសុខ (គុក) និងបូជនីយដ្ឋាន




ផែនទីឧក្រិដ្ឋកម្មខ្មែរក្រហម ដែលបង្ហាញទីតាំងសម្លាប់ មន្ទីរសន្តិសុខ និងបូជនីយដ្ឋាននៅទូទាំងប្រទេសកម្ពុជា។ ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអតីតការិយាល័យស្រាវជ្រាវមួយរបស់ គម្រោងស្ដីអំពីអំពើប្រល័យពូជសាសន៍ នៅប្រទេសកម្ពុជា នៃសាកលវិទ្យាល័យយ៉េល។ គម្រោងនេះ ត្រូវបង្កើតឡើងដោយលោកសាស្ត្រាចារ្យ បេន គៀនិន។ អ្នកស្រាវជ្រាវបង្គោល៖ ផេង ពង្សរ៉ាស៊ី ជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និង ថូម៉ាស វ៉េលមែន មកពីនាយកដ្ឋានភូមិសាស្ត្រ នៃសាកលវិទ្យាល័យ ខែនស្តេត។



ក្រុមការងារផ្នែកផលិតខ្សែភាពយន្តឯកសារ និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) នៃមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុង
រៀបចំថតរូប និងវីដេអូ ពីខ្សែរថភ្លើង នៅឃុំទឹកពុះ ខេត្តកំពង់ឆ្នាំង។ រូបថត អ៊ិច មករា



"បើទោះបីជាមនុស្សរាប់លាននាក់ត្រូវសម្លាប់ក៏ដោយ ក៏ប៉ុន្តែនៅមានអ្នករស់រានមានជីវិតជាច្រើនលាននាក់ផ្សេងទៀត អាច និយាយប្រាប់យើងពីជីវិតរបស់គាត់ដែរ។ ជាងនេះទៅទៀត នៅមានជនដៃដល់ជាច្រើនទៀត ក៏នៅរស់រានមានជីវិតដែរ។"

ឡេង រតនៈ ផលិតករខ្សែភាពយន្តឯកសាររឿង "ក្បង់ទឹកទន្លេ"។

វត្ថុតូចមួយ តែមានតម្លៃសម្រាប់ជីវិត។ នេះជារូបថតផ្កាថ្នក់ទឹក ដែលដុះចេញពីចំបើងនៅតាមវាលស្រែ ក្រោយពីច្រូតកាត់រួច។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនដែលធ្វើការនៅតាមវាលស្រែតែងតែឃើញផ្កាថ្នក់ទឹក។ ប្រជាជនមួយចំនួនបានយល់ថា យ៉ាងហោចណាស់ភាពស្រស់ត្រកាលនៅតែមាន បើទោះបីជានៅក្នុងឋាននរកក៏ដោយ។ ជនរងគ្រោះនៃរបបខ្មែរក្រហមមួយរូបបានរំឭកថា ខ្លួនធ្លាប់ឃើញវាលស្រែជាច្រើនពោរពេញទៅដោយផ្កាថ្នក់ទឹក នៅពេលដែលគាត់រស់នៅតំបន់៥។ រៀងរាល់រដូវច្រូតកាត់ វាលស្រែទាំងអស់គ្របដណ្តប់ដោយផ្កាថ្នក់ទឹក ដែលបានរំឭកដល់អនុស្សាវរីយ៍នៃការជួបជុំគ្រួសារ និងផ្ទះសម្បែង។ នៅក្នុងស្ថានភាពដ៏លំបាក និងអស់សង្ឃឹម ទិដ្ឋភាពដ៏តូចមួយនេះបានជួយសង្គ្រោះជីវិតជនរងគ្រោះម្នាក់នោះ។ រូបថត : ផាត ពិសិដ្ឋ។

# ផ្កាយក្រពើ

ក្រុមគ្រួសាររបស់ខ្ញុំត្រូវជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ពួកយើងបានធ្វើដំណើរទៅកាន់ស្រុកកំណើតម្តាយរបស់យើងដែលស្ថិតនៅឯខេត្តតាកែវ។ កាលនោះ នៅឆ្នាំ១៩៧៥ មានពាក្យចចាមអារាមបានលេចឡើងថា យើងអាចត្រឡប់ទៅផ្ទះវិញ។ ថ្ងៃមួយ ខ្មែរក្រហមបានមកប្រាប់យើងឲ្យរៀបចំបង្វេច និងធ្វើដំណើរទៅ។ យើងសង្ឃឹមក្នុងចិត្តថា នេះគឺជាការធ្វើដំណើរវិលត្រឡប់ទៅផ្ទះយើងវិញ ។

ខ្មែរក្រហមបានបញ្ជាយើងឲ្យឡើងរថភ្លើង។ នៅលើរថភ្លើងមានមនុស្សម្នាជាច្រើន ដែលយើងមិនអាចអង្គុយបាន។ បងស្រីរបស់ខ្ញុំម្នាក់មានកូនស្រីមួយ ដែលទើបតែមានអាយុពីរ-បីខែប៉ុណ្ណោះ។ នាងមានឈ្មោះថា តាន់ កែវកិតាណា។ យើងគ្រប់គ្នាចាប់ផ្តើមព្រួយបារម្ភចំពោះរឿងរ៉ាវដែលអាចកើតឡើងបន្ទាប់។ នៅពេលយប់ ពូរបស់ខ្ញុំឈ្មោះ កែវ ឈឿន បានក្រឡេកមើលទៅផ្កាយ ហើយដំណាលប្រាប់យើងអំពីផ្កាយក្រពើ។

ផ្កាយក្រពើ គឺជារឿងព្រេងនិទានដែលយើងបានរៀនកាលពីនៅកុមារ។ នេះជារឿងនិទាន ដែលស្តីអំពីក្រពើមួយក្បាល ដែលបានសាងអំពើល្អ ហើយបានក្លាយទៅជាផ្កាយនៅលើមេឃ។ ផ្កាយក្រពើតំណាងឲ្យសេចក្តីសង្ឃឹម ទិសដៅ និងសេចក្តីល្អ។ គេអាចសម្លឹងរកផ្កាយក្រពើនៅលើមេឃ ដែលផ្កាយនេះអាចជួយប្រាប់ទិសដៅបាន។

នៅពេលធ្វើដំណើរតាមរថភ្លើងនាពេលរាត្រី ពូរបស់ខ្ញុំតែងតែចង្អុលប្រាប់ខ្ញុំអំពីផ្កាយក្រពើនោះ។ គាត់បានប្រាប់យើងទាំងអស់គ្នាថា យើងកំពុងធ្វើដំណើរត្រឡប់ទៅទីក្រុងភ្នំពេញ។ យើងទាំងអស់គ្នាមានសេចក្តីសោមនស្សរីករាយ ដោយដឹងថានឹងបានត្រឡប់ទៅផ្ទះវិញ។ បើទោះបីជា យើងត្រូវធ្វើដំណើរជាច្រើនថ្ងៃ និងឈប់តាមផ្លូវជាច្រើនកន្លែងក៏ដោយ ក៏យើងមិនខ្វល់ដែរ ឲ្យតែយើងធ្វើដំណើរលើទិសដៅត្រូវ។ រំពេចនោះ យើងក៏បានដឹងការពិត ។ បន្ទាប់ពីធ្វើដំណើរទៅដល់ខេត្តពោធិ៍សាត់ ប្រជាជនជាច្រើនត្រូវបញ្ជាឲ្យចុះពីទូរថភ្លើង។ អ្នកដំណើរផ្សេងទៀតត្រូវធ្វើដំណើរបន្តទៅកាន់ខេត្តបាត់ដំបង នៅក្បែរព្រំដែនប្រទេសថៃ។ ប៉ុន្តែ ការធ្វើដំណើររបស់យើងមិនទាន់បានបញ្ចប់នៅឡើយទេ។ ពេលគឺការធ្វើដំណើររបស់យើងទើបតែចាប់ផ្តើមតែប៉ុណ្ណោះ។

សព្វថ្ងៃនេះ ខ្ញុំនៅតែនឹកឃើញដល់ផ្កាយក្រពើ។ ក្នុងអំឡុងពេលមួយនោះ ផ្កាយក្រពើបាននាំមកនូវក្តីសង្ឃឹម និងភាពរីករាយដល់យើង បើទោះបីជា វាហាក់ដូចជាការស្រមើស្រមៃក៏ដោយ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបំបែកចេញពីគ្នា។ យើងចាប់ផ្តើមជីវិតថ្មីរៀងៗខ្លួន ជាមួយនឹង ការអត់ឃ្លាន ការធ្វើការធ្ងន់ និងអំពើប្រល័យពូជសាសន៍។ ខ្ញុំយល់ថា ខ្លួនខ្ញុំមានសំណាង ដែលបានរស់រានមានជីវិតពីរបបដ៏ឃោរឃៅ ស្របពេលដែលសមាជិកក្រុមគ្រួសាររបស់ខ្ញុំជាច្រើនបានស្លាប់បាត់បង់ជីវិត ក៏ដូចជា កូនស្រីរបស់បងស្រីខ្ញុំ និងពូរបស់ខ្ញុំជាដើម។ តាំងពីពេលនោះមក ខ្ញុំបានប្តូរការយល់ឃើញរបស់ខ្ញុំចំពោះផ្កាយក្រពើ។

**យុត្តិធម៌ ការចងចាំ ការផ្សះផ្សា**

9 789995 060268